ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក
BAMC FINANCE PLC.

# របាយការណ៍
# ប្រចាំឆ្នាំ២០២២

ផ្ទះលេខ315A ផ្លូវលេខ217 ភូមិសំបួរ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ទូរស័ព្ទ: 023 911000 /010 555 165
សារអេឡិចត្រូនិច: info@bamc.com.kh គេហទំព័រ: www.bamc.com.kh

# មាតិការ


១ សារប្រធានក្រុមប្រឹក្សាភិបាល ........ ១
២ សារប្រធាននាយកប្រតិបត្តិ ........ ២
៣ សារវតាគ្រឹះស្ថាន ........ ២
៣.១ ប្រវត្តិគ្រឹះស្ថាន ........ ៣
៣.២ ទស្សនៈវិស័យ ........ ៣
៣.៣ បេសកកម្ម ........ ៣
៣.៤ តម្លៃស្នូល បីអេអឹមស៊ី ........ ៣
៣.៥ បាវចនា ........ ៣
៣.៦ រចនាសម្ព័ន្ធគ្រឹះស្ថាន ........ ៤
៣.៧ ភាគទុនិក និងក្រុមប្រឹក្សាភិបាល ........ ៥
៣.៨ គណៈគ្រប់គ្រង ........ ៦
៤ លទ្ធផលប្រតិបត្តិការ ........ ៩
៤.១ ប្រតិបត្តិការអាជីវកម្ម ........ ៩
៤.២ ផលិតផល និងសេវាកម្មហិរញ្ញវត្ថុ ........ ១២
៤.៣ អភិបាលកិច្ចធនធានមនុស្ស ........ ១២
៤.៣.១ ព័ត៌មានបុគ្គលិកនិយោជិត ........ ១២
៤.៣.២ អត្ថប្រយោជន៍បុគ្គលិកនិយោជិត ........ ១២
៤.៣.៣. ការអភិវឌ្ឍបុគ្គលិកនិយោជិត ........ ១៣
៤.៣.៤. កម្រិតចំណាត់ថ្នាក់មុខតំណែង និងការលើកទឹកចិត្ត ........ ១៣
៤.៣.៥ អភិក្រមដឹកនាំឆ្នាំ២០២០ និងសិក្ខាបទការងារ ទាំង ១០-ស ........ ១៤
៤.៣.៦ បទបញ្ជាផ្ទៃក្នុង និងវិធានទោសវិន័យធនធានមនុស្ស ........ ១៤
៤.៤ សវនកម្ម និងការត្រួតពិនិត្យផ្ទៃក្នុង ........ ១៥
៤.៥ ហានិភ័យ និងអនុលោមភាព ........ ១៥
៤.៦ គោលនយោបាយ និងនីតិវិធី វិស្សលប្ប៉ូវីង ........ ១៦
៤.៧ ក្របខ័ណ្ឌការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ........ ១៧
៥ សម្រង់របាយការណ៍ហិរញ្ញវត្ថុក្រោយសវនកម្មឆ្នាំ២០២១ ........ ១៧
៥.១ របាយការណ៍របស់ក្រុមប្រឹក្សាភិបាល ........ ១៧
៥.២ របាយការណ៍របស់សវនករឯករាជ្យ ........ ២១
៥.៣ តារាងតុល្យការ ........ ២៤
៥.៤ របាយការណ៍លទ្ធផល ........ ២៥
៥.៥ របាយការណ៍បម្រែបម្រួលមូលធន ........ ២៦
៥.៦ របាយការណ៍លំហូរសាច់ប្រាក់ ........ ២៨

## ១ សារប្រធានក្រុមប្រឹក្សាភិបាល



ចាប់តាំងពីដើម២០២២ ស្ថានភាពសេដ្ឋកិច្ចពិភពលោកពុំមានស្ថិរភាព និងបង្កក្តីព្រួយបារម្ភពីវិបត្តិសកល ដោយសារការកើនឡើងអតិផរណារួមមានការកើនឡើងថ្លៃចំណាយ ប្រចាំថ្ងៃ ការប្រែប្រួលអត្រាប្តូរប្រាក់ ផលប៉ះពាល់លើថ្លៃដើម ការបន្តរាំងស្ទះខ្សែច្រវាក់ផ្គត់ផ្គង់ ការផ្ទុះឡើង ជំងឺកូវីដ-១៩ និងការអូសបន្លាយសង្គ្រាមរុស្ស៊ី-អ៊ុយក្រែន ជាដើម។

ស្របពេលជាមួយគ្នានេះដែរ សេដ្ឋកិច្ចកម្ពុជាក៏បានថយចុះ ដោយសាររងផលប៉ះពាល់ពីវិបត្តិសកលទាំងនោះផងដែរ។ ដើម្បីឆ្លើយតបនឹងស្ថានភាពនេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រ និងវិធានការជាច្រើន ហើយរាជរដ្ឋាភិបាលក៏បានបញ្ចេញកញ្ចប់ថវិកា ដើម្បីគាំទ្រ និងស្តារសកម្មភាពសេដ្ឋកិច្ច និងអាជីវកម្មខ្នាតតូចបំផុត និងខ្នាតតូច ព្រមទាំងក្រុមគ្រួសារ ដែលក្រីក្រ និងងាយរងគ្រោះ ដើម្បីកាត់បន្ថយកំណើនអតិផរណា និងរក្សាកំណើនសេដ្ឋកិច្ចក្នុងឆ្នាំ២០២២ និងឆ្នាំបន្តបន្ទាប់។ ជាលទ្ធផល យន្តការទាំងនេះរបស់រាជរដ្ឋាភិបាលបានជួយកាត់បន្ថយអតិផរណា និងជំរុញកំណើន សេដ្ឋកិច្ចយ៉ាងមានប្រសិទ្ធភាព នៅក្នុងកំលុងឆ្នាំ២០២២ផងដែរ។ ស្ថានភាពសេដ្ឋកិច្ចកម្ពុជាបានស្ទុះងើបឡើងវិញបន្តិចម្តងៗ ទៅរកភាពប្រក្រតីវិញលឿនជាងការរំពឹងទុកក្នុងឆ្នាំ២០២១ ដោយសារការបើកសកម្មភាពសេដ្ឋកិច្ចឡើងវិញ។

ប្រឈមនឹងវិបត្តិដែលបានអូសបន្លាយអស់រយៈពេលបីឆ្នាំកន្លងមកនេះ ប្រព័ន្ធធនាគារនិងហិរញ្ញវត្ថុនៅតែបន្តដើរតួនាទីយ៉ាងសំខាន់ក្នុងការគាំទ្រសកម្មភាពសេដ្ឋកិច្ច ជាពិសេសវិស័យដែលរងផលប៉ះពាល់។ សម្រាប់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក បានធ្វើការគណនានៃព័ត៌មានហិរញ្ញវត្ថុបន្ថែម ដោយបានយោងទៅតាមនិយមន័យនៃប្រកាស និងសេចក្តីជូនដំណឹងដែលពាក់ព័ន្ធ និងត្រូវបានកំណត់នៅក្នុងកថាខណ្ឌដូចបានបង្ហាញខាងក្រោមនេះ ដែលជាផ្នែកដ៏សំខាន់នៃព័ត៌មានហិរញ្ញវត្ថុបន្ថែម និងគួរត្រូវបានសំដៅរួមគ្នាជាមួយនឹងសេចក្តីសង្ខេប នៃការប្រតិបត្តិតាម ដូចមានខាងក្រោម៖

- អនុបាតសាច់ប្រាក់ងាយស្រួល ធ៧-០២-៤៨ ប្រ.ក >១០០%
- ទ្រព្យសកម្មសុទ្ធ ឬមូលនិធិផ្ទាល់សុទ្ធ ធ៧-០៧-១៣២ ប្រ.ក ១៤.០០០.០០០ ពាន់រៀល
- អនុបាតសាធនភាព ធ៧-០២-១៣៣ ប្រ.ក ៧៥.០៤%
- ដើមទុនអប្បបរមា ធ៧-០០-០៦ ប្រ.ក ១៣.០៦៦.១៥៩ ពាន់រៀល

ក្នុងនាមជាប្រធានក្រុមប្រឹក្សាភិបាល ប៊ីអេអឹមស៊ី ខ្ញុំសូមឆ្លៀតឱកាសថ្លែងអំណរគុណដល់មន្ត្រីទាំងអស់ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ធនាគារជាតិ នៃកម្ពុជា និងជាពិសេសអគ្គនាយកដ្ឋានត្រួតពិនិត្យ ដែលបានផ្តល់ជាការណែនាំ ការគាំទ្រ និងការផ្តល់ជាអនុសាសន៍ល្អៗផ្សេងៗ មកកាន់គ្រឹះស្ថានយើងខ្ញុំ។

តាំងនាមឱ្យក្រុមប្រឹក្សាភិបាល ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់ថ្នាក់ដឹកនាំ និងបុគ្គលិកនិយោជិត គ្រប់លំដាប់ថ្នាក់ របស់គ្រឹះស្ថាន ដែលបានបន្តខិតខំប្រឹងប្រែងបំពេញការងារ និងតស៊ូជំនះរាល់គ្រប់ឧបសគ្គជាមួយគ្រឹះស្ថាន តាំងពីដើម រហូតមកទល់នឹងពេលនេះ ដោយទទួលបានលទ្ធផលដែលគួរឱ្យកត់សំគាល់មួយនៅក្នុងឆ្នាំនេះ។ ដោយឡែកគ្រឹះស្ថាន នឹងនៅតែបន្តនូវ ទស្សនៈវិស័យ បេសកកម្ម និងប្រើប្រាស់នូវយុទ្ធសាស្ត្រថ្មីៗ ដើម្បីរីកចម្រើនព្រមគ្នា ក្នុងវិស័យមីក្រូហិរញ្ញវត្ថុ ក្នុងការស្វែងរកប្រាក់ចំណេញ ប្រកបដោយតម្លាភាព គណនេយ្យភាព ក្រមសីលធម៌វិជ្ជាជីវៈ គុណធម៌ ការទទួលខុសត្រូវខ្ពស់នៅក្នុងសហគមន៍របស់យើង និងរក្សាឱ្យបាននូវនិរន្តរភាពអាជីវកម្ម នាឆ្នាំបន្តបន្ទាប់ទៅមុខទៀត។

ខ្ញុំសូមថ្លែងអំណរគុណ ជូនចំពោះអតិថិជនទាំងអស់ ដែលបានបន្តដំណើរជាមួយ ប៊ីអេអឹមស៊ី ក្នុងន័យបង្កើតផលប្រយោជន៍ឱ្យគ្នាទៅវិញទៅមក ក្នុងនាមជា ដៃគូអាជីវកម្មជាទីទុកចិត្ត គឺ ប៊ីអេអឹមស៊ី។

ជាចុងក្រោយចំពោះសមិទ្ធិផលរបស់ ប៊ីអេអឹមស៊ី ក្នុងឆ្នាំ២០២២ នេះ គឺពិតជាបានមកពីការចូលរួមចំណែកគាំទ្រយ៉ាងសំខាន់ របស់ធនាគារជាតិ នៃកម្ពុជា ការប្តេជ្ញាចិត្តខ្ពស់របស់សមាជិកក្នុងក្រុមគ្រួសារ ប៊ីអេអឹមស៊ី និងជាពិសេសអតិថិជនដែលមានភក្តីភាព របស់ ប៊ីអេអឹមស៊ី ទាំងអស់។ សូមអរគុណ និងថ្លែងអំណរគុណជាអនេកប្បការ។

**លោក ហ៊ុន ពេជ្រ**

**(ប្រធានក្រុមប្រឹក្សាភិបាល)**

## ២ សាររបស់ប្រធាននាយកប្រតិបត្តិ



សួស្តីឆ្នាំ ២០២២! ខ្ញុំបាទឈ្មោះ KANG DONG HYUN ជាប្រធាននាយកប្រតិបត្តិនៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក។ សមាជិកក្នុងក្រុមគ្រួសារ ប៊ីអេអឹមស៊ី របស់យើង បានចូលរួមចំណែកយ៉ាងសំខាន់ ក្នុងវិស័យសេដ្ឋកិច្ចជាតិកម្ពុជា ដែលកំពុងប្រឈមនឹងការលំបាកខ្លាំងក្នុងឆ្នាំ២០២២។ ក្នុងនាមជាអ្នកផ្តល់ហិរញ្ញ-ប្បទានជាន់ខ្ពស់ និងបានខិតខំប្រឹងប្រែងយ៉ាងសកម្ម នៅក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ នៅកម្ពុជា ដើម្បីធានាបាននូវស្ថិរភាពហិរញ្ញវត្ថុ និងសុខុមាលភាព រស់នៅរបស់ប្រជាជនទូទៅនៅក្នុងប្រទេសកម្ពុជា។

ជាមួយនឹងបទពិសោធន៍ដ៏យូរលង់របស់យើង ក្នុងវិស័យហិរញ្ញវត្ថុ និងការយល់ដឹងខ្ពស់ពីបច្ចេកវិទ្យាដ៏ជឿនលឿនដូចពេលបច្ចុប្បន្ន យើងបានខិតខំប្រឹងប្រែងផ្តល់ឱ្យប្រជាជនកម្ពុជានូវស្ថិរភាពហិរញ្ញវត្ថុ ការកាត់បន្ថយនូវភាពក្រីក្រ និងការផ្តល់ជាមូលនិធិសង្គ្រោះបន្ទាន់ជាចាំបាច់សម្រាប់អាជីវកម្ម និងការគិតពិចារណាខ្ពស់ពីភាពងាយស្រួល និងការបម្រើសេវាកម្មល្អដល់អតិថិជនរបស់យើងជាអាទិភាពចម្បង។

យើងនឹងបង្កើតឱ្យមានវប្បធម៌ហិរញ្ញវត្ថុ ឈ្នះ-ឈ្នះ តាមរយៈការផ្តល់ និងការគាំទ្រផ្នែកហិរញ្ញវត្ថុឆ្ពោះទៅរកមនុស្សជាទីស្រឡាញ់ និងជាដៃគូអាជីវកម្មដ៏គួរជាទីទុកចិត្តពីសំណាក់អតិថិជនគ្រប់លំដាប់ថ្នាក់។

យើងចង់កសាងឱ្យបាននូវការគ្រប់គ្រង និងការច្នៃប្រឌិតដ៏ល្អមួយ ប្រកបដោយនិរន្តរភាព ដែលនឹងនាំមកនូវសុភមង្គល និងការអភិវឌ្ឍដល់អតិថិជនរបស់យើង។ ផ្អែកលើបញ្ហានេះ យើងនឹងគិតអំពីអ្វីដែលយើងអាចធ្វើបានសម្រាប់ការចូលរួមចំណែក និងការអភិវឌ្ឍសង្គមរបស់យើង ហើយយើងនឹងចាប់ផ្តើមអនុវត្តវា។

វប្បធម៌របស់យើងដែលផ្តល់តម្លៃដល់អតិថិជនជាអាទិភាពទីមួយ មិនមែនគ្រាន់តែដើម្បីជួបអតិថិជនក្នុងនាមជាស្ថាប័នហិរញ្ញវត្ថុប៉ុណ្ណោះនោះទេ ប៉ុន្តែយើង គឺបានគិតអំពីភាពរីកលូតលាស់នៃក្រុមគ្រួសារ មិត្តល្អ និងភាពជាដៃគូអាជីវកម្មដែលគួរជាទីទុកចិត្ត អាចពឹងផ្អែកលើគ្នា និងប្រាស្រ័យទាក់ទងគ្នាបានល្អ។

យើងនឹងខិតខំប្រឹងប្រែង និងផ្តល់ការគាំទ្រដល់អតិថិជននិងក្រុមគ្រួសាររបស់យើង រហូតដល់ថ្ងៃដែលអ្នកពេញចិត្ត ហើយយើងនឹងចូលរួមវិភាគទានឱ្យបានច្រើន ក្នុងការអភិវឌ្ឍប្រទេសកម្ពុជា។

ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ដល់ក្រុមគ្រួសារ និងអតិថិជនទាំងអស់របស់ ប៊ីអេអឹមស៊ី ហើយយើងសន្យាថានឹងនៅតែជាក្រុមគ្រួសារតែមួយ ជាមួយអតិថិជនរបស់យើង ដើម្បីទទួលបានជីវិតកាន់តែល្អប្រសើរឡើង ស្របតាមបាវចនាផ្ទៃក្នុងរបស់យើងថា (ប៊ីអេអឹមស៊ី! សម្រាប់ក្រុមគ្រួសារ, ប៊ីអេអឹមស៊ី! ល្អដាច់គេ)។

សូមអរគុណច្រើន!!!

ព្រះរាជាណាចក្រកម្ពុជា
ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក
BAMC FINANCE PLC
KINGDOM OF CAMBODIA

**លោក KANG DONG HYUN**
**ប្រធាននាយកប្រតិបត្តិ**

## ៣ សាវតាគ្រឹះស្ថាន

### ៣.១ ប្រវត្តិគ្រឹះស្ថាន

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក គឺជានាមករណ៍ថ្មី ដែលបានផ្លាស់ប្តូរមកពីនាមករណ៍ចាស់នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ តាកា ម៉ាយក្រូហ្វាយនែន ភីអិលស៊ី ត្រូវបានបង្កើតឡើងជាក្រុមហ៊ុនមហាជនទទួលខុសត្រូវមានកម្រិត ដោយទទួលបាននូវវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ MOC-20937940 ពណ.ចបព និងមានអត្តលេខក្រុមហ៊ុន ០០០០៨៣៤៧ នៅកាលបរិច្ឆេទចុះបញ្ជីថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០១៤។ គ្រឹះស្ថានក៏បានទទួល អាជ្ញាបណ្ណប្រកបអាជីវកម្មជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ លេខ ម.ហ-៤៥ មានឈ្មោះ ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក ពីធនាគារជាតិ នៃកម្ពុជា នៅថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩។

សកម្មភាពចម្បងគ្រឹះស្ថាន គឺផ្តល់នូវសេវាកម្មមីក្រូហិរញ្ញវត្ថុ ដែលប្រកបដោយស្ថិរភាពចំពោះសហគ្រាសធុនតូច និងមធ្យម និងគ្រួសារដែលមានចំណូលទាបនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ពុំមានការផ្លាស់ប្តូរជាសារវន្តសម្រាប់សកម្មភាព អាជីវកម្មចម្បងរបស់គ្រឹះស្ថាន ក្នុងកំឡុងការិយបរិច្ឆេទនេះទេ។

សកម្មភាពធុរកិច្ចគ្រឹះស្ថាន បច្ចុប្បន្នកំពុងពង្រីកប្រតិបត្តិការសេវាហិរញ្ញវត្ថុ ទៅតាមបណ្តា រាជធានី/ខេត្តក្រុង/ស្រុក ដើម្បីផ្តល់នូវភាពងាយស្រួលជូនអតិថិជនដែលមានតម្រូវការឥណទាន ក្នុងគោលបំណងទ្រទ្រង់សេដ្ឋកិច្ចគ្រួសារ ឧត្តរជីវិត អាជីវកម្ម ការវិនិយោគផ្ទាល់ខ្លួន និងការសង្គ្រោះបន្ទាន់រយៈពេលខ្លី។

### ៣.២ ទស្សនៈវិស័យ

"ជាធនាគារិកល្អឆ្នើមបំផុត សម្រាប់ក្រុមគ្រួសារទាំងឡាយ ក្នុងព្រះរាជាណាចក្រកម្ពុជា"

### ៣.៣ បេសកកម្ម

"កសាងវិបុលភាពល្អប្រសើរបំផុត សម្រាប់សហគមន៍យើងទាំងអស់គ្នា"

### ៣.៤ តម្លៃស្នូល ប៊ីអេអឹមស៊ី

- សេវាកម្មល្អឆ្នើមបំផុត ៖ យើងតែងតែផ្តល់សេវាកម្មឱ្យលើសការរំពឹងទុករបស់អតិថិជន។
- ងាយស្រួលទំនាក់ទំនង ៖ យើងតែងតែនៅជាមួយអតិថិជនរបស់យើង។
- សីលធម៌ ៖ យើងតែងតែគោរពឱ្យតម្លៃអតិថិជនរបស់យើង។
- អតិថិជន ៖ យើងតែងតែបម្រើសេវាកម្មដល់អតិថិជនរបស់យើង ដោយអស់ពីចិត្ត និងបេះដូង។

### ៣.៥ បាវចនា

៣.៥.១ បាវចនាខាងក្រៅ " ដៃគូអាជីវកម្មជាទីទុកចិត្តរបស់លោកអ្នក គឺ ប៊ីអេអឹមស៊ី "

៣.៥.២ បាវចនាខាងក្នុង " ប៊ីអេអឹមស៊ី! សម្រាប់ក្រុមគ្រួសារ, ប៊ីអេអឹមស៊ី! ល្អដាច់គេ "

## ៣.៦ រចនាសម្ព័ន្ធគ្រឹះស្ថាន



## ៣.៧ ភាគទុនិក និងក្រុមប្រឹក្សាភិបាល

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក ត្រូវបានបង្កើតឡើងដោយ ភាគទុនិកចំនួន ០២រូប ដែលជានីតិបុគ្គល និងរូបវន្តបុគ្គល។ ជាមួយគ្នានោះដែរ គ្រឹះស្ថានក៏មានក្រុមប្រឹក្សាភិបាល ចំនួន ០៥រូប ដែលជាសមាជិកក្នុងពេលបច្ចុប្បន្ន ដោយមាន ០២រូប ជាភាគទុនិក ដោយត្រូវបានអនុម័ត និងទទួលស្គាល់ពី ធនាគារជាតិនៃកម្ពុជា ក្រសួងពាណិជ្ជកម្ម និងអគ្គនាយកដ្ឋានពន្ធដារ ទាំង ០៥រូប ក្នុងនាមជាសមាជិកក្រុមប្រឹក្សាភិបាលស្របតាមច្បាប់ និងបទប្បញ្ញត្តិ នៃព្រះរាជាណាចក្រកម្ពុជា។ ខាងក្រោមនេះ គឺជាបណ្តាភាគទុនិក និងសមាជិកក្រុមប្រឹក្សាភិបាល របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក នាពេលបច្ចុប្បន្ន៖

| **ភាគទុនិក** | **ភាគរយនៃភាគហ៊ុន** |
|---|---|
| ១. ក្រុមហ៊ុន ភីណាត់ ខេមបូ ខបភើរេសិន តំណាងដោយ លោក ហ៊ុន ពេជ្រ | ៩៧.៨១% |
| ២. លោក KANG DONG HYUN ជាជនជាតិកូរ៉េខាងត្បូង | ២.១៩% |

| **ក្រុមប្រឹក្សាភិបាល** | **តួនាទី និងមុខតំណែង** |
|---|---|
| ១. លោក ហ៊ុន ពេជ្រ | ប្រធានក្រុមប្រឹក្សាភិបាល |
| ២. លោក KANG DONG HYUN | អភិបាល និងជាប្រធាននាយកប្រតិបត្តិ |
| ៣. លោក ចុង សុជាត | អភិបាល និងជានាយក |
| ៤. លោក PARK BYUNG KWON | អភិបាល (លាលែងនៅថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២១) |
| ៥. លោក KIM CHUL WOONG | អភិបាលឯករាជ្យ (លាលែងនៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០២១) |

**គណៈកម្មការក្រុមប្រឹក្សាភិបាល៖**

| **គណៈកម្មការសវនកម្ម** | **តួនាទី និងមុខតំណែង** |
|---|---|
| ១. លោក PARK BYUNG KWON | ប្រធានគណៈកម្មការ |
| ២. លោក បូ សុធារ៉ា | មន្ត្រីសវនកម្មផ្ទៃក្នុងជាន់ខ្ពស់ និងជាសមាជិក |

| **គណៈកម្មការហានិភ័យ និងប្រតិបត្តិតាម** | **តួនាទី និងមុខតំណែង** |
|---|---|
| ១. លោក KIM CHUL WOONG | ប្រធានគណៈកម្មការ |
| ២. លោក ថា កែវប្រសិទ្ធិ | ប្រធាន នាយកដ្ឋានហានិភ័យ & ប្រតិបត្តិតាម និងជាសមាជិក |

## ៣.៨ គណៈគ្រប់គ្រង



### ប្រធាននាយកប្រតិបត្តិ និងជាអភិបាល

លោក Kang Dong Hyun ជាជនជាតិកូរ៉េខាងត្បូង និងជាប្រធាននាយកប្រតិបត្តិ នៃ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក ក្នុងកំឡុងដើមឆ្នាំ២០១៩។ មុននឹងមកកាន់មុខតំណែងនេះ លោកធ្លាប់ត្រូវបានគេជ្រើសរើសឱ្យធ្វើជានាយកប្រតិបត្តិ នៅធនាគារភ្នំពេញពាណិជ្ជកម្មជា កំឡុងឆ្នាំ២០១៣ មកដល់ ២០១៨។ លោកទទួលបានសញ្ញាបត្រអនុបណ្ឌិត ផ្នែកហិរញ្ញវត្ថុសាជីវកម្មនៅប្រទេសកូរ៉េ។ ទន្ទឹមនឹងនេះដែរ ក្នុងតួនាទីភាពជាអ្នកដឹកនាំ លោកក៏បានចូលរួមយ៉ាងសកម្ម ក្នុងការអភិវឌ្ឍដល់វិស័យធនាគារ និងហិរញ្ញវត្ថុ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។



### នាយកប្រតិបត្តិ និងជាអភិបាល

លោក ចុង សុជាត ជាជនជាតិខ្មែរ ។ បច្ចុប្បន្នលោកជានាយកប្រតិបត្តិនៃគ្រឹះស្ថានហិរញ្ញវត្ថុ ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក លោកបានបញ្ចប់ការសិក្សា បរិញ្ញាបត្រផ្នែកសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យន័រតុន ក្នុងឆ្នាំ២០០១។ លោកមានបទពិសោធន៍ក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុរយៈពេលជាង ១៨ឆ្នាំ ដែលមានមុខតំណែងដូចជា ប្រធានគ្រប់គ្រងឥណទានសហ-គ្រាសខ្នាតតូច និងមធ្យម នាយកសាខា ប្រធានគ្រប់គ្រងឥណទានជាន់ខ្ពស់ និងអ្នកគ្រប់គ្រងទូទៅនៅធនាគារអន្តរជាតិធំៗ ក្នុងស្រុកផងដែរ។

នៅឆ្នាំ ២០១៩ លោកបានចូលបម្រើការងារជាមួយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក ដោយមានតួនាទី និងមុខតំណែង ជាអភិបាលរបស់គ្រឹះស្ថាន ដើម្បីកែលំអការគ្រប់គ្រងផ្ទៃក្នុងនិងអភិបាលកិច្ចល្អ នៅកន្លែងធ្វើការ ក្នុងព្រះរាជាណាចក្រកម្ពុជា។



### នាយក នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន

លោក **សុខ ស៊ីថន** មានតួនាទីជា នាយក នៃនាយកដ្ឋានព័ត៌មានវិទ្យា ។

លោកបានបញ្ចប់ការសិក្សាផ្នែកបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកវិទ្យាសាស្ត្រព័ត៌មានវិទ្យា នៅក្នុងសាកលវិទ្យាល័យក្នុងស្រុក នៅឆ្នាំ ២០០៦ ។

លោកធ្លាប់មានបទពិសោធនៅក្នុងអាជីពបច្ចេកវិទ្យា ក្នុងវិស័យអប់រំ និងវិស័យធនាគារ និងហិរញ្ញវត្ថុ រយៈពេលជាង ១២ឆ្នាំ ដែលមានមុខតំណែង ដូចជាសាស្ត្រាចារ្យ នាយករងដេប៉ាតេម៉ង់ និងជាប្រធានការិយាល័យក្រុមហ៊ុនប្រេងឥន្ធនៈដ៏ធំមួយនៅក្នុងស្រុកផងដែរ។ នៅឆ្នាំ ២០១៩ លោកក៏បានចូលបម្រើការងារជាមួយ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក ក្នុងមុខតំណែង ជានាយក នាយកដ្ឋានបច្ចេកវិទ្យាព័ត៌មាន ដើម្បីធានាដល់ដំណើរការ និងសុវត្ថិភាព នៃប្រព័ន្ធធនាគារស្នូលរបស់គ្រឹះស្ថាន។



## ប្រធាន នាយកដ្ឋានមុខងារប្រតិបត្តិតាម និងជាសមាជិក នៃ គណៈកម្មការប្រតិបត្តិតាម និងហានិភ័យ

លោក **ថា កែវប្រសិទ្ធិ** នាយក នាយកដ្ឋានមុខងារប្រតិបត្តិតាម លោកបានចូលបម្រើការងារចាប់ពីខែមិថុនា ឆ្នាំ២០២១។ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រក្នុងឆ្នាំ ២០០២ និងថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រង ក្នុងឆ្នាំ២០០៩ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង ។ លោកក៏ធ្លាប់បានចូលរួមវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈជាច្រើន ទាក់ទងនឹងវិស័យធនាគារ និងហិរញ្ញវត្ថុ ហើយលោកមានបទពិសោធន៍ការងារជាង ១៥ឆ្នាំ ក្នុងមុខតំណែងចាប់ពីធារី (Teller) រហូតដល់ជាប្រធានសាខានៅក្នុងវិស័យធនាគារ។ ទន្ទឹមនឹងនេះដែរ យោងលើតួនាទីបច្ចុប្បន្ន លោកតែងតែដឹកនាំគ្រឹះស្ថាន និងនិយោជិតទាំងអស់ប្រតិបត្តិតាមគោលនយោបាយ និងនីតិវិធីនានារបស់គ្រឹះស្ថាន ក៏ដូចជា អនុលោមភាព តាមប្រកាស ពីអាជ្ញាធរអាណាព្យាបាល ធនាគារជាតិ នៃកម្ពុជា ក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានពន្ធដារ និងរួមទាំង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងព្រះរាជាណាចក្រកម្ពុជា។ ហើយលោកបានលាឈប់ពីការងារនៅថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២៣។



## នាយក នាយកដ្ឋានប្រតិបត្តិការ

លោក **នឿក សារ៉េត** នាយក នាយកដ្ឋានប្រតិបត្តិការ លោកបម្រើការនៅការិយាល័យកណ្តាល នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក នៅឆ្នាំ ២០១៤ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញគ្រប់គ្រង ពីសាកលវិទ្យាល័យធនធានមនុស្ស (HRU) ក្នុងឆ្នាំ២០១១។

លោកធ្លាប់មានបទពិសោធន៍ក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ រយៈពេលជាង ១២ឆ្នាំ ដែលមានតួនាទីដូចជា មន្ត្រីឥណទាន ប្រធានឥណទាន នាយករងសាខា នាយកសាខា និងប្រធានផ្នែកសវនកម្មផ្ទៃក្នុង នៅប្រតិបត្តិករឥណទានជនបទ និងគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្នុងស្រុក។ ទន្ទឹមគ្នានេះដែរ លោកក៏ធ្លាប់បានឆ្លងកាត់វគ្គបណ្តុះបណ្តាលជំនាញសវនកម្ម ជំនាញឥណទាន និងព្រមទាំងមានបទពិសោធន៍ និងចំណេះដឹង យ៉ាងគ្រប់គ្រាន់ ក្នុងការគ្រប់គ្រង ដឹកនាំ និងបណ្តុះបណ្តាលបុគ្គលិក ក្នុងផ្នែកប្រតិបត្តិការអាជីវកម្ម និងជួយជម្រុញឱ្យគ្រឹះស្ថានមានភាពរីកចម្រើន និងទទួលបាននូវប្រាក់ចំណេញ។ ហើយលោកបានលាឈប់ពីការងារនៅថ្ងៃទី២០ ខែមេសា ឆ្នាំ២០២៣។



## ប្រធានផ្នែកកម្ចី និងវិភាគឥណទាន

លោក **ឆឹយ សុភ័ក្រ** ប្រធានផ្នែកកម្ចី និងវិភាគឥណទាន លោកបានចូលបម្រើការងារចាប់ពីខែកញ្ញា ឆ្នាំ២០២២។ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រក្នុងឆ្នាំ ២០០២ និងថ្នាក់បរិញ្ញាបត្រ ផ្នែកគ្រប់គ្រង ក្នុងឆ្នាំ២០០៩ ពីសាកលវិទ្យាល័យជាតិគ្រប់គ្រង ។ លោកក៏ធ្លាប់បានចូលរួមវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈជាច្រើន ទាក់ទងនឹងវិស័យធនាគារ និងហិរញ្ញវត្ថុ ហើយលោកមានបទពិសោធន៍ការងារជាង ១៣ឆ្នាំ នៅក្នុងវិស័យធនាគារ។

## អនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ



លោក **ជ្រា ប៉េងណា** នាយក នាយកដ្ឋានហិរញ្ញវត្ថុ លោកបម្រើការងារនៅការិយាល័យកណ្តាល នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក ហើយលោកបានចូលបម្រើការងារចាប់ពីខែឧសភា ឆ្នាំ២០២២។ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកគណនេយ្យពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ក្នុងឆ្នាំ២០១១។

ទន្ទឹមនឹងនោះលោកក៏ធ្លាប់បានចូលរួមវគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈជាច្រើនទាក់ទងនឹងវិស័យធនាគារ និងហិរញ្ញវត្ថុ និងពន្ធដារ។ ជួយមួយបទពិសោធន៍ការងារក្នុងវិស័យគណនេយ្យ និងហិរញ្ញវត្ថុជាង១០ឆ្នាំលោកបានអភិវឌ្ឍន៍សមត្ថភាពរបស់ខ្លួនពីបុគ្គលិកគណនេយ្យ រហូតដល់តួនាទីនេះ។ ហើយលោកបានលាឈប់ពីការងារនៅថ្ងៃទី៣១ ខែមិនា ឆ្នាំ២០២៣។

## មន្ត្រីជាន់ខ្ពស់ នាយកដ្ឋានសវនកម្មផ្ទៃក្នុង



លោក **បូ សុធារ៉ា** មន្ត្រីសវនកម្មផ្ទៃក្នុងជាន់ខ្ពស់ បច្ចុប្បន្ន លោកកំពុងបម្រើការនៅការិយាល័យកណ្តាល នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក ដែលជានាមករណ៍ថ្មី បានផ្លាស់ប្តូរមកពី តាកា ម៉ាយក្រូហ្វាយនែន ភីអិលស៊ី ចាប់ពីនៅឆ្នាំ២០១៧ រហូតមកដល់បច្ចុប្បន្ន។ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ធនាគារ និងហិរញ្ញវត្ថុ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យា-សាស្រ្តសេដ្ឋកិច្ច ក្នុងឆ្នាំ២០១៤។ លោកមានធ្លាប់បទពិសោធន៍ក្នុងវិស័យធនាគារ និងហិរញ្ញវត្ថុ រយៈពេលជាង ០៨ឆ្នាំ ដែលមានមុខតំណែងដូចជា មន្ត្រីឥណទាន មន្ត្រីសវនករការិយាល័យកណ្តាល និងមន្ត្រីសវនកម្មផ្ទៃក្នុងជាន់ខ្ពស់ ។ ទន្ទឹមនឹងនេះដែរ លោកក៏ធ្លាប់បានចូលរួមវគ្គបណ្តុះបណ្តាលជាច្រើន លើជំនាញសវនកម្ម ជំនាញឥណទាន និងព្រមទាំងមានបទពិសោធន៍ ចំណេះដឹង និងជំនាញ យ៉ាងគ្រប់គ្រាន់ ក្នុងការគ្រប់គ្រង ដឹកនាំ និងចូលរួមបណ្តុះ-បណ្តាលបុគ្គលិក ក្នុងផ្នែកសវនកម្ម ប្រតិបត្តិការ និងផ្នែកផ្សេងៗទៀត ក្នុងការជួយជម្រុញឱ្យគ្រឹះស្ថានជៀសវាងពីហានិភ័យប្រតិបត្តិការ និងសក្តានុពល នៃហានិភ័យផ្សេងៗទៀត។

## មន្ត្រីជាន់ខ្ពស់ នាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាល និងជាសមាជិកគណៈកម្មការធនធានមនុស្ស



លោក **ភេម សេងហ៊ត់** មន្ត្រីធនធានមនុស្ស និងរដ្ឋបាលជាន់ខ្ពស់ បច្ចុប្បន្ន លោកកំពុងបម្រើការនៅការិយាល័យកណ្តាល នៃគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក ដែលជានាមករណ៍ថ្មី បានផ្លាស់ប្តូរមកពី តាកា ម៉ាយក្រូហ្វាយនែន ភីអិលស៊ី នៅឆ្នាំ ២០១៧ រហូតមកដល់បច្ចុប្បន្ន។ លោកបានបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ជំនាញ ធនាគារ និងហិរញ្ញវត្ថុ ពីវិទ្យាស្ថានសហប្រតិបត្តិការអន្តរជាតិកម្ពុជា ក្នុងឆ្នាំ២០១៨។ លោកមានបទពិសោធន៍ក្នុងវិស័យអប់រំ និងវិស័យធនាគារ និងហិរញ្ញវត្ថុ រយៈពេលជាង ០៦ឆ្នាំ ដែលមានមុខតំណែងដូចជា បុគ្គលិកការិយាល័យ មន្ត្រីឥណទាន មន្ត្រីរដ្ឋបាល នៅអង្គការសហប្រតិបត្តការអន្តរជាតិកម្ពុជា។ ទន្ទឹមនឹងនេះដែរ លោកក៏ធ្លាប់បានឆ្លងកាត់វគ្គបណ្តុះបណ្តាលជំនាញធនធានមនុស្ស ជំនាញរដ្ឋបាល និងព្រមទាំងមាន បទពិសោធន៍ ចំណេះដឹង និងជំនាញវិជ្ជាជីវៈ យ៉ាងគ្រប់គ្រាន់ ក្នុងការគ្រប់គ្រង ដឹកនាំ និងបណ្តុះបណ្តាលបុគ្គលិក ក្នុងផ្នែកធនធានមនុស្ស រដ្ឋបាល និងផ្នែកផ្សេងៗទៀត ក្នុងការជួយជ្រោមជ្រែង មូលធនធនធានមនុស្សរបស់គ្រឹះស្ថានដើម្បីក្លាយជាធនាគារិកដ៏ល្អឆ្នើមបំផុតក្នុងព្រះរាជាណាចក្រកម្ពុជា។

## ៤ លទ្ធផលប្រតិបត្តិការ
## ៤.១ ប្រតិបត្តិការអាជីវកម្ម

នៅដើមឆ្នាំ២០២២ វិស័យហិរញ្ញវត្ថុ បានដើរតួនាទីយ៉ាងសំខាន់មួយក្នុងការជួយជ្រុមជ្រែងទ្រទ្រង់ដល់សេដ្ឋកិច្ចជាតិ និងធុរកិច្ចឱ្យមានការរីកចម្រើន។ ទន្ទឹមនឹងដំណាក់កាលនៃការរីករាលដាលជម្ងឺកូវីដ-១៩ វិស័យមីក្រូ-ហិរញ្ញវត្ថុ នៅតែបន្តការអភិវឌ្ឍន៍ និងដើរតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមចំណែកជាមួយរដ្ឋាភិបាលកម្ពុជាក្នុងការប្រយុទ្ធជាមួយប្រជាពលរដ្ឋក្នុងសហគមន៍ ដែលរងផលប៉ះពាល់ដោយវីរ៉ុសកូវីដ-១៩ តាមរយៈការផ្តល់សេវាកម្មហិរញ្ញវត្ថុសង្គ្រោះបន្ទាន់ ដល់អាជីវកម្មខ្នាតតូច និងមធ្យម សេដ្ឋកិច្ចគ្រួសារ ឬផ្តល់ការរៀបចំឥណទានឡើងវិញឲ្យបានល្អប្រសើរបំផុតសម្រាប់សហគមន៍របស់ពួកគេ។ ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក បានចាប់ផ្តើមបង្កើតឡើងនូវប្រាក់កម្ចីសង្គ្រោះបន្ទាន់ ប្រាក់កម្ចីរយៈពេលខ្លី ផ្តល់ដល់អាជីវកម្មថ្មីៗជាច្រើន ដើម្បីលើកកម្ពស់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋកម្ពុជា ស្របទៅតាមយុទ្ធសាស្ត្រចតុកោណ របស់រាជរដ្ឋាភិបាលកម្ពុជា និងអភិក្រមដឹកនាំទាំង៥ *(ឆ្លុះកញ្ចក់ > ងូតទឹក > ដុសក្អែល > ព្យាបាល > វះកាត់)* របស់សម្តេចអគ្គមហាសេនាបតីតេជោ *ហ៊ុន សែន* ដែលបានដឹកនាំប្រទេសកម្ពុជាឱ្យមានសុខសន្តិភាពយូរអង្វែង *(អរគុណសន្តិភាព)* ។

ក្នុងកំឡុងឆ្នាំ២០២២ ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក បានធ្វើវិសោធនកម្មយ៉ាងច្រើន ទៅលើគោលនយោបាយផ្ទៃក្នុង នីតិវិធី ផលិតផល សេវាកម្ម និងរបៀបរបបនៃការដឹកនាំថ្មី រួមទាំងការបង្កើនផលិតភាពការងារ និងប្រសិទ្ធភាពការងារ ដើម្បីប្រឈមនឹងការរីករាលដាលវីរ៉ុសកូវីដ-១៩ ជាសកល ឆ្ពោះទៅកាន់ឧត្តមភាពនៃការប្រកួតប្រជែង ក្នុងការចាប់យកចំណែកទីផ្សារនៃប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី ឬសកលភាវូបនីយកម្ម។ ដើម្បីបង្កើនចំណែកទីផ្សាររបស់ប៊ីអេអឹមស៊ី ស្របតាមគោលដៅចក្ខុវិស័យ បេសកកម្ម និងគុណតម្លៃជាស្នូលរបស់ ប៊ីអេអឹមស៊ី ដែលបានដាក់ចេញឱ្យអនុវត្តទៅគ្រប់បុគ្គលិក និងថ្នាក់គ្រប់គ្រងជាន់ខ្ពស់ ដោយត្រូវខិតខំប្រឹងប្រែងបំពេញការងារ និងធ្វើការដោយភាពឆ្លាតវៃ ក្នុងការស្វែងរកប្រាក់ចំណេញប្រកបដោយ គុណធម៌ក្នុងការគាំពារអតិថិជន ក្រមសីលធម៌វិជ្ជាជីវៈ សមធម៌ការងារ អភិបាលកិច្ចក្រុមហ៊ុន ការត្រួតពិនិត្យផ្ទៃក្នុង និងអនុលោមភាពតាម ច្បាប់ និងបទប្បញ្ញត្តិនានា របស់ព្រះរាជាណាចក្រកម្ពុជា។

គិតត្រឹមចុងឆ្នាំ២០២២ ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក មានការិយាល័យប្រតិបត្តិការចំនួន ០៣(បី) រួមមានដូចខាងក្រោម៖

១. ទីស្នាក់ការកណ្តាល (សាខាចំការដូង)
  - អាសយដ្ឋាន៖ ផ្ទះលេខ ៣១៥អា ផ្លូវលេខ ២១៧ ភូមិសំបួរ សង្កាត់ ដង្កោ ខណ្ឌ ដង្កោ រាជធានីភ្នំពេញ។
  - ទូរស័ព្ទទំនាក់ទំនងលេខ៖ ០២៣ ៩១១ ០០០

២. ការិយាល័យសាខា ភ្នំពេញថ្មី
  - អាសយដ្ឋាន៖ ផ្ទះលេខ ១៥៣សេ ផ្លូវលេខ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌ សែនសុខ រាជធានីភ្នំពេញ។
  - ទូរស័ព្ទទំនាក់ទំនងលេខ៖ ០២៣ ៩១១ ០០៥

៣. ការិយាល័យសាខា ស្រុកកៀនស្វាយ
  - អាសយដ្ឋាន៖ ផ្ទះលេខ អា-៤៥ ផ្លូវជាតិលេខ ១ ភូមិ ភូមិធំ ឃុំ ភូមិធំ ស្រុក កៀនស្វាយ ខេត្ត កណ្តាល។
  - ទូរស័ព្ទទំនាក់ទំនងលេខ៖ ០២៣ ៩១១ ០០៧
  - ម៉ោងធ្វើការ
    - ថ្ងៃធ្វើការ៖ ថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រ (៧:៣០ ព្រឹក - ៤:៣០ ល្ងាច)
    - ម៉ោងបម្រើការ៖ ថ្ងៃច័ន្ទ ដល់ ថ្ងៃសុក្រ (៧:៣០ ព្រឹក - ៤:០០ ល្ងាច)
  - បណ្តាញទំនាក់ទំនងរបស់ ប៊ីអេអឹមស៊ី៖

- លោក ថា កែវប្រសិទ្ធិ    លេខទំនាក់ទំនង៖០៧០ ៥៥៥ ០៨១
  អ៊ីម៉ែល៖ keopraseth.tha@bamc.com.kh
- លោក បូ សុធារ៉ា    លេខទំនាក់ទំនង៖០១៦ ៥៥៥ ៣២៨
  អ៊ីម៉ែល៖ sotheara.bo@bamc.com.kh
- លោក នឿក សារ៉េត    លេខទំនាក់ទំនង៖០៧០ ៥៥៥ ៧៣៦
  អ៊ីម៉ែល៖ saret.noeuk@bamc.com.kh

គិតជាលទ្ធផលប្រចាំឆ្នាំ២០២២ គ្រឹះស្ថាន ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក បានផ្តល់សេវាកម្មប្រាក់កម្ចីជូនដល់អតិថិជនទាំងខាងក្នុង និងខាងក្រៅ បានចំនួនសរុប ១០ រាជធានី/ខេត្ត ៣៥ ក្រុង/ស្រុក/ខណ្ឌ ដែលសម្រេចបានជាលទ្ធផល ដូចមានលម្អិតខាងក្រោម៖

១. អតិថិជនសកម្មសរុប មានចំនួន ១៨៩នាក់ ក្នុងឆ្នាំ២០២២ បើប្រៀបធៀបទៅឆ្នាំ២០២១ មានចំនួន ២១៩នាក់ ដោយថយចុះអតិថិជនសកម្មសរុបចំនួន ៣០នាក់ គិតជាភាគរយ ស្មើនឹង (១៣.៦៩%)
២. ផលបត្រឥណទានសរុប មានចំនួន ១៦,៨០០.២៣លានរៀល ក្នុងឆ្នាំ២០២២ បើប្រៀបធៀបទៅឆ្នាំ២០២១ ផលបត្រឥណទានសរុបមានចំនួន ១៦,៧០០.២៥លានរៀល ដោយមានការកើនឡើង ចំនួន ៩៩,៩៨លានរៀល គិតជាភាគរយស្មើនឹង ០,៥៩%
៣. ទំហំឥណទានគិតជាមធ្យម ផ្តល់ទៅអតិថិជនក្នុង ០១នាក់ មានចំនួនស្មើនឹង ៨៨.៨៩លានរៀល ក្នុងឆ្នាំ២០២២ បើប្រៀបធៀបទៅឆ្នាំ២០២១ ទំហំឥណទានគិតជាមធ្យមផ្តល់ទៅអតិថិជនក្នុង ០១នាក់ មានចំនួនស្មើនឹង ៧៦.២៥លានរៀល
៤. ផលបត្រឥណទាន គិតជារូបិយវត្ថុជាតិ (រៀល) អនុវត្តន៍តាមប្រកាសរបស់ធនាគារជាតិ នៃកម្ពុជា ឱ្យបាន ១០ % គ្រឹះស្ថានសម្រេចបាន ១៣.៦៣% ក្នុងឆ្នាំ២០២២
៥. ឥណទានផ្តល់ទៅអតិថិជន ក្នុងឆ្នាំ២០២២ និង ២០២១ រួមមានដូចខាងក្រោម៖

**(ក). វិភាគតាមប្រភេទរូបិយប័ណ្ណ**

| | ២០២២ | | ២០២១ |
|---|---|---|---|
| | **ដុល្លារអាមេរិក** | **គិតជាពាន់រៀល** | **ដុល្លារអាមេរិក** |
| ដុល្លារអាមេរិក | ៣,៧៨២,៥១២ | ១៥,៥៧២,៦០២ | ៣,៥១៧,១៤៩ |
| ខ្មែររៀល | ៣០៧,៤៥០ | ១,២៦៥,៧៧២ | ៥៦៨,៩៤០ |
| | ៤,០៨៩,៩៦២ | ១៦,៨៣៨,៣៧៤ | ៤,០៨៦,០៨៩ |

**(ខ). វិភាគតាមកត្តាសេដ្ឋកិច្ច**

| | ២០២២ | | | ២០២១ |
|---|---|---|---|---|
| | **គិតជាភាគរយ** | **ដុល្លារអាមេរិក** | **គិតជាពាន់រៀល** | **ដុល្លារអាមេរិក** |
| កសិកម្ម | ១ % | ៤១,៨៤២ | ១៧២,២៦៤ | ១៥០,៣០៧ |
| សំណង់ | ៤,៧១ % | ១៩៧,៩០២ | ៨១៤,៧៦៣ | ៣៧១,៨០៥ |
| គ្រួសារ | ៣៣,២៥ % | ១,៣៩៦,៦៩១ | ៥,៧៥០,១៧៧ | ១,០០៩,៨៥៥ |
| សេវាកម្ម | ១០,២១ % | ៤២៨,៦៧៤ | ១,៧៦៤,៨៥១ | ៧៩៤,៨៧៣ |
| ជំនួញ និងពាណិជ្ជកម្ម | ១៨,៦០ % | ៧៨១,៣៣១ | ៣,២១៦,៧៤០ | ៩៣៥,២០៧ |
| មធ្យោបាយដឹកជញ្ជូន | ០,៧៧% | ៣២,៥៣៧ | ១៣៣,៩៥៥ | ៣៨,៩៩១ |

| | | | | |
|---|---|---|---|---|
| ផ្សេងៗទៀត | ៣១,៤៥ % | ១,២១០,៩៨៥ | ៤,៩៨៥,៦២៤ | ៧៨៥,០១១ |
| | ១០០ % | ៤,០៨៩,៩៦២. | ១៦៨៣៨៣៧៤. | ៤,០៨៦,០៨៩. |

(គ). វិភាគតាមសម្ព័ន្ធភាគី

| | ២០២២ | | | ២០២១ |
|---|---|---|---|---|
| | គិតជាភាគរយ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| ឥណទានទៅអតិថិជនខាងក្រៅ | ៨៦,៥៤ % | ៣,៥៣៩,៥០៥ | ១៤,៥៧២,១៤៣ | ៣,៥៩០,០៨០ |
| ឥណទានទៅបុគ្គលិក | ១៣.៤៦ % | ៥៥០,៤៥៧ | ២,២៦៦,២៣១ | ៤៩៦,០០៩ |
| | ១០០ % | ៤,០៨៩,៩៦២ | ១៦,៨៣៨,៣៧៤ | ៤,០៨៦,០៨៩ |

## ៤.២ ផលិតផល និងសេវាកម្មហិរញ្ញវត្ថុ

សេវាកម្មហិរញ្ញវត្ថុ៖ ១. ឥណទានអាជីវកម្ម ២. ឥណទានរយៈពេលខ្លី ៣. ឥណទានគេហដ្ឋាន ៤. ឥណទានរថយន្ត

ផលិតផលហិរញ្ញវត្ថុ៖ ១. រូបិយវត្ថុជាតិ (រៀល) ២. រូបិយបណ្ណអន្តរជាតិ (ដុល្លារអាមេរិក)

## ៤.៣ អភិបាលកិច្ចធនធានមនុស្ស

### ៤.៣.១ ព័ត៌មានបុគ្គលិកនិយោជិត

គិតមកត្រឹមចុងឆ្នាំ២០២២ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ **ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក** មានបុគ្គលិកនិយោជិតបម្រើការងាររាប់បញ្ចូលទាំង បុគ្គលិកបរទេស ០១រូប ជាជនជាតិកូរ៉េខាងត្បូង ដូចមានលម្អិតក្នុងតារាងខាងក្រោម៖

| ល.រ | មុខតំណែង / នាយកដ្ឋាន / ការិយាល័យសាខា | ចំនួននិយោជិក | ប្រុស | ស្រី |
|---|---|---|---|---|
| 1 | ប្រធាននាយកប្រតិបត្តិ | ០១ | ០១ | |
| 2 | នាយក | ០១ | ០១ | |
| 3 | នាយកដ្ឋានប្រតិបត្តិតាម និងហានិភ័យ | ០១ | ០១ | |
| 4 | នាយកដ្ឋានព័ត៌មានវិទ្យា | ០១ | ០១ | |
| 5 | នាយកដ្ឋានហិរញ្ញវត្ថុ | ០៣ | ០២ | ០១ |
| 6 | នាយកដ្ឋានសវនកម្មផ្ទៃក្នុង | ០១ | ០១ | |
| 7 | នាយកដ្ឋានប្រតិបត្តិការ | ០១ | ០១ | |
| 8 | នាយកដ្ឋានធនធានមនុស្ស និងរដ្ឋបាល | ០១ | ០១ | |
| 9 | នាយកដ្ឋានទីផ្សារ | ០២ | ០២ | |
| 10 | សាខាភ្នំពេញថ្មី | ០៦ | ០៣ | ០៣ |
| 11 | សាខាកៀនស្វាយ | ០៥ | ០៣ | ០២ |
| 12 | សាខាការិយាល័យកណ្តាល (ចំការដូង) | ០៣ | ០១ | ០២ |
| **សរុបចំនួននិយោជិក** | | **២៦** | **១៨** | **០៨** |

### ៤.៣.២ អត្ថប្រយោជន៍បុគ្គលិកនិយោជិត

**ក. អត្ថប្រយោជន៍និយោជិករយៈពេលខ្លី**

ប្រាក់ឈ្នួល ប្រាក់បៀវត្ស វិភាគទានសន្តិសុខសង្គម ប្រាក់បង់ការឈប់សម្រាកប្រចាំឆ្នាំ ប្រាក់បង់ការឈប់សម្រាកពេលឈឺ អត្ថប្រយោជន៍បន្ថែម និងអត្ថប្រយោជន៍មិនមែនសាច់ប្រាក់ គឺត្រូវបានវាស់វែងដោយផ្អែកលើមូលដ្ឋានមិនគិតអប្បហារ និងត្រូវបានទទួលស្គាល់ជាចំណាយ នៅពេលដែលនិយោជិតទាំងនោះបានបំពេញការងារឱ្យក្រុមហ៊ុន។

ប្រាក់សំណងបង្គររយៈពេលខ្លី រួមមានប្រាក់បង់ការឈប់សម្រាកប្រចាំឆ្នាំ ដែលត្រូវបានកំណត់ ដោយបានទទួលស្គាល់ជាចំណាយនៅពេលនិយោជិតទាំងនោះ បានបម្រើការងារដោយបង្កើនសិទ្ធិទទួលបានរបស់ ពួកគាត់នៅថ្ងៃអនាគត។ អវត្តមានរយៈពេលខ្លីមិនបង្គរសម្រាប់ទូទាត់ ដូចជាការឈប់សម្រាកឈឺ ត្រូវបានទទួលស្គាល់នៅពេលដែលអវត្តមាននោះកើតឡើង ហើយប្រសិនបើការឈប់សម្រាកនោះមិនត្រូវបានប្រើប្រាស់ទាំងស្រុងនៅក្នុងការិយបរិច្ឆេទទេ និយោជិតនឹងមិនត្រូវបានទូទាត់ជូនជាសាច់ប្រាក់នៅចុងការិយបរិច្ឆេទ ឬ នៅពេលដែលលាឈប់ពីក្រុមហ៊ុនឡើយ។ អត្ថប្រយោជន៍បន្ថែម គឺត្រូវបានទទួលស្គាល់ជាចំណាយនៅពេលដែលមានកាតព្វកិច្ចផ្លូវច្បាប់ ឬកាតព្វកិច្ច ដែលបង្កើតឡើងនាពេលបច្ចុប្បន្នតម្រូវឱ្យមានការបង់ប្រាក់ ដែលជាលទ្ធផលកើតចេញពីព្រឹត្តិការណ៍កន្លងមក និងនៅពេលដែលមានការប៉ាន់ស្មានជាក់លាក់ អាចត្រូវបានធ្វើឡើងពីចំនួននៃកាតព្វកិច្ច។

**ខ. អត្ថប្រយោជន៍ពីការបញ្ឈប់ការងារ**

អត្ថប្រយោជន៍ពីការបញ្ឈប់ការងារ គឺជាសំណងដែលត្រូវបង់ជូននិយោជិតដោយការបញ្ឈប់ពីការងារ មុនពេលថ្ងៃចូលនិវត្តន៍ ឬការស្ម័គ្រចិត្តរបស់និយោជិត ដើម្បីទទួលយកអត្ថប្រយោជន៍ទាំងនោះជាថ្នូរនឹងការបញ្ឈប់ពីការងារដោយការស្ម័គ្រចិត្ត។ អត្ថប្រយោជន៍ទាំងនោះត្រូវបានទទួលស្គាល់ជាបំណុល និងចំណាយនៅពេលដែលក្រុមហ៊ុនមានគម្រោងបញ្ឈប់ការងារនិយោជិតជាផ្លូវការច្បាស់លាស់ ដោយមិនមានលក្ខខណ្ឌណាដែលគម្រោងនេះត្រូវដកចេញ។ ក្នុងករណីការបញ្ឈប់ដោយស្ម័គ្រចិត្ត ដោយនិយោជិតលើសពីតម្រូវការអត្ថប្រយោជន៍នោះ ត្រូវបានគណនាផ្អែកទៅលើចំនួននិយោជិតដែលរំពឹងថានឹងទទួលការស្នើសុំនេះ។ នៅពេលដែលអត្ថប្រយោជន៍ពីការបញ្ឈប់ការងារហួសការជំពាក់កំណត់លើសពី ១២ខែ បន្ទាប់ពីចុងនៃការិយបរិច្ឆេទ អត្ថប្រយោជន៍នោះត្រូវបានធ្វើអប្បហារទៅជាតម្លៃបច្ចុប្បន្នដោយផ្អែកលើលទ្ធផលទីផ្សារនៅចុងការិយបរិច្ឆេទ។

## ៤.៣.៣ ការអភិវឌ្ឍបុគ្គលិកនិយោជិត

នៅឆ្នាំ២០២២ នេះ ប៊ីអេអឹមស៊ី មានផែនការជាក់លាក់ ក្នុងការបណ្តុះបណ្តាលដល់និយោជិកដែលមានស្រាប់ និងថ្មី ដែលត្រូវបានធ្វើការតម្រង់ទិស ដើម្បីធ្វើឱ្យប្រសើរឡើងនូវជំនាញ សមត្ថភាព ចំណេះដឹង និងការអនុវត្តការងារ យោងទៅតាមការពិពណ៌នាការងាររៀងៗខ្លួន ដោយត្រូវអនុវត្តឱ្យស្របទៅតាមយុទ្ធសាស្ត្រ គោលដៅ ចក្ខុវិស័យ បេសកកម្ម គុណតម្លៃស្នូល និងបាវចនាខាងក្នុង **ប៊ីអេអឹមស៊ី! សម្រាប់ក្រុមគ្រួសារ ប៊ីអេអឹមស៊ី! ល្អជាច់គេ។**

ប៊ីអេអឹមស៊ី បានបើកវគ្គបណ្តុះបណ្តាលដល់បុគ្គលិកនិយោជិតជាទៀងទាត់ នៅរៀងរាល់ពេលព្រឹកថ្ងៃសៅរ៍ចាប់ពីម៉ោង ០៨ នាទីព្រឹក ដល់ម៉ោង ១២ ថ្ងៃត្រង់ ដល់បុគ្គលិកនិយោជិកទាំងអស់ មកពីគ្រប់ការិយាល័យសាខា នៅសាលប្រជុំនៃការិយាល័យកណ្តាលរបស់គ្រឹះស្ថាន ដោយមានគ្រូបង្គោលជាតំណាង ដែលត្រូវបានតែងតាំងចេញពីនាយកដ្ឋានជំនាញនីមួយៗ ក្នុងការហ្វឹកហ្វឺន និងបង្ហាត់បង្រៀន ដល់បុគ្គលិកនិយោជិក។

គោលបំណងសំខាន់នៃការបណ្តុះបណ្តាលនេះ គឺដើម្បីពង្រឹងដល់បុគ្គលិកគ្រប់ជាន់ថ្នាក់ឱ្យមានសមត្ថភាពនិងជំនាញពេញលេញក្នុងការងារប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ មានទំនុកចិត្តលើខ្លួនឯង និងសាមគ្គីភាពតាមរយៈការចែករំលែកមតិយោបល់ទាំងវិជ្ជមាន និងអវិជ្ជមាន ក្នុងន័យស្ថាបនា ជាមួយមិត្តរួមការងារ និងគណៈគ្រប់គ្រងរបស់គ្រឹះស្ថានក្នុងការពួតដៃគ្នាកសាង ប៊ីអេអឹមស៊ី ឱ្យកាន់តែមានភាពរីកចម្រើនដូចពេលបច្ចុប្បន្ន និងទៅអនាគត ដើម្បីក្លាយខ្លួនទៅជាធនាគាររីកដ៏ល្អឆ្នើមបំផុត នាយុគសម័យបច្ចេកវិទ្យាដ៏ទំនើបនេះ។

## ៤.៣.៤ កម្រិតចំណាត់ថ្នាក់មុខតំណែង និងការលើកទឹកចិត្ត

ចាប់តាំងពីដើមឆ្នាំ២០២២ មក ប៊ីអេអឹមស៊ី បានធ្វើកំណែទម្រង់យ៉ាងច្រើន លើកម្រិតចំណាត់ថ្នាក់ និងមុខតំណែងនីមួយៗជា **១១កម្រិត** ដោយរាប់ចាប់ពីមន្ត្រីថ្នាក់ទាបរហូតទៅដល់ថ្នាក់គ្រប់គ្រងជាន់ខ្ពស់ ដែលមានភ្ជាប់មកជាមួយនូវ ការលើកទឹកចិត្តទាំងបែបហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ រួមមានដូចជា៖ ការតំឡើងឋានៈតួនាទី ការតែងតាំងតួនាទីស្តីទី ការផ្តល់ជារង្វាន់ ការផ្តល់ជាលិខិត ឬប័ណ្ណសរសើរ ដល់បុគ្គលិកនិយោជិកដែលសម្រេចបានលទ្ធផលការងារល្អប្រសើរនិងអត្ត

ប្រយោជន៍បន្ថែមផ្សេងៗ ដែលផ្តល់ជូនដោយប្រធាននាយកប្រតិបត្តិរបស់គ្រឹះស្ថាន ទៅកាន់បុគ្គលិកនិយោជិកគ្រប់ជាន់ថ្នាក់ ដែលបានខិតខំប្រឹងប្រែងប្រណាំងប្រជែងបំពេញការងារ និងសម្រេចបានលទ្ធផលល្អដាច់គេ លើសផែនការគ្រោងទុក នៅក្នុងយុទ្ធនាការប្រតិបត្តិការអាជីវកម្មរបស់គ្រឹះស្ថាន ដែលបានដាក់ចេញឱ្យអនុវត្ត ។

ទន្ទឹមនឹងនេះដែរ សម្រាប់ការលើកទឹកចិត្តបែបហិរញ្ញវត្ថុជាច្រើន ក៏ត្រូវបានបង្កើតឡើងសម្រាប់ផ្តល់ជូន បុគ្គលិកនិយោជិកគ្រប់ជាន់ថ្នាក់ ដែលសុទ្ធតែមានចែងនៅក្នុងគោលនយោបាយ និងនីតិវិធី ថ្មីៗរបស់គ្រឹះស្ថាន ដែលទទួលបានការអនុម័ត ពីក្រុមប្រឹក្សាភិបាល ដោយមានជំនួយពីគណៈកម្មការធនធានមនុស្ស ជាអ្នកទទួលបន្ទុក អនុវត្តឱ្យស្របតាមច្បាប់ និងបទប្បញ្ញត្តិ របស់ព្រះរាជាណាចក្រកម្ពុជា។ ជាការពិតណាស់ ឆ្នាំនេះ ប៊ីអេអឹមស៊ី បានរៀបចំឱ្យមានសិក្ខាសាលាប្រចាំឆ្នាំ តាមរយៈដំណើរកំសាន្ត ជូនដល់បុគ្គលិកនិយោជិក និងថ្នាក់គ្រប់គ្រងទាំងអស់។

### ៤.៣.៥ អភិក្រមដឹកនាំឆ្នាំ២០២២ និងសិក្ខាបទការងារ ទាំង ១០-ស

- អនុសាសន៍ ៖ ការផ្លាស់ប្តូរ > ការប្រឈម > កិច្ចសហប្រតិបត្តិការ > ការទំនាក់ទំនង
- គុណទាន ៖ អត្តចារិក > លទ្ធភាពសង > មូលធនទ្រព្យសម្បត្តិ > ទ្រព្យតម្កល់ធានា > លក្ខខណ្ឌព្រមព្រៀង
- ៣ ការពារ ៖ អភិបាលកិច្ចក្រុមហ៊ុន > អនុលោមភាពបទប្បញ្ញត្តិ > សុភវិនិច្ឆ័យ
- ៣ កុំ ៖ យកសោហ៊ុយក្រៅផ្លូវការ > ចូលរួមអំពើពុករលួយ > ជាប់ពាក់ព័ន្ធបទឧក្រិដ្ឋ
- សិក្ខាបទការងារទាំង (១០-ស) ៖ សម្រិត > សម្រួល > សម្អាត > សន្សំសំចៃ > សម្តី > សម្ងាត់ > សុវត្ថិភាព > សន្តិសុខ > ស្ថិរភាព > សើច

### ៤.៣.៦ បទបញ្ជាផ្ទៃក្នុង និងវិធានទោសវិន័យធនធានមនុស្ស

- បទបញ្ជាផ្ទៃក្នុង ប៊ីអេអឹមស៊ី ត្រូវបានតាក់តែងឡើងជាគោលការណ៍ប្រតិបត្តិ និងអនុម័តដោយក្រុមប្រឹក្សាភិបាល ស្របតាមច្បាប់ស្តីពីការងារ នៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើបច្ចុប្បន្នភាពជាប្រចាំ អនុលោមតាមសារាចរណ៍ ឬសេចក្តីណែនាំនានារបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។ គោលការណ៍ផ្ទៃក្នុងនេះ ក៏បានឃើញ និងបញ្ជាក់ថាត្រឹមត្រូវ ដោយសាលារាជធានីភ្នំពេញ នៅថ្ងៃទី១២ ខែតុលា ឆ្នាំ២០២០ ។

- គោលការណ៍វិធានទោសវិន័យធនធានមនុស្ស ត្រូវបានធ្វើវិសោធនកម្មដោយគណៈកម្មការធនធានមនុស្ស ក្នុងឆ្នាំ២០២០ ដើម្បីកំណត់ចេញជាក្រមប្រតិបត្តិសីលធម៌វិជ្ជាជីវៈ និងជានីតិវិធីពិន័យដល់ អ្នកណាម្នាក់ដែលជាប់ពាក់ព័ន្ធនឹងកំហុសធ្ងន់ ។ គោលការណ៍ផ្ទៃក្នុងនេះ ទាមទារតម្រង់ឆ្ពោះទៅសមធម៌ ក្នុងលក្ខខណ្ឌព្រមព្រៀង នៃកិច្ចសន្យាការងារ ការរំលាយកិច្ចសន្យាការងារ និងការបណ្តេញចេញពីការងារ។

## ៤.៤ សវនកម្ម និងការត្រួតពិនិត្យផ្ទៃក្នុង

គណៈកម្មការសវនកម្ម ដែលមាននាយកដ្ឋានសវនកម្មផ្ទៃក្នុង ជាសេនាធិការ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការត្រួតពិនិត្យផ្ទៃក្នុង ទាំងលើដំណើរការ និងប្រតិបត្តិការអាជីវកម្ម របស់គ្រឹះស្ថាន គ្រប់ការិយាល័យសាខាទាំងអស់ ដែលបានប្រគល់សិទ្ធិពេញលេញពីគ្រឹះស្ថាន និងធនាគារជាតិ នៃកម្ពុជា ដែលបានអនុម័តទទួលស្គាល់ នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៨ ដល់មន្ត្រីសវនករផ្ទៃក្នុងជាន់ខ្ពស់ ក្នុងការអនុវត្តការងារ ឬការបំពេញតួនាទីរបស់ខ្លួន ប្រកបដោយឯករាជ្យភាព និងការស្វែងរករបកគំហើញ ដែលមិនបានអនុលោម តាមច្បាប់ និងបទប្បញ្ញត្តិ របស់ព្រះរាជាណាចក្រកម្ពុជា។

គិតមកត្រឹមចុងឆ្នាំ២០២២ នាយកដ្ឋានសវនកម្មផ្ទៃក្នុង មានបុគ្គលិកបម្រើការងារសរុបចំនួន ០១រូប និងគណៈកម្មការសវនកម្មមានសមាជិកចំនួន ០៣រូប ដោយប្រធានគណៈកម្មការសវនកម្ម ជាសមាជិក ០១រូប នៅក្នុងក្រុមប្រឹក្សាភិបាលរបស់គ្រឹះស្ថាន។ ទន្ទឹមនឹងនេះដែរ នាយកដ្ឋានសវនកម្មផ្ទៃក្នុង គឺមានផែនការប្រចាំឆ្នាំយ៉ាងច្បាស់លាស់មួយដោយបានរៀបចំឡើងនៅរៀងរាល់បំណាច់ឆ្នាំនីមួយៗ ដើម្បីដាក់ជូនគណៈកម្មការសវនកម្មរបស់ខ្លួន ធ្វើការត្រួតពិនិត្យ និងអនុម័ត នឹងដាក់ឱ្យអនុវត្តជាផ្លូវការ ដើម្បីប្រសិទ្ធិភាពការងារ នៅឆ្នាំបន្តបន្ទាប់ទៀត។

ការរៀបចំកម្មវិធីសវនកម្មរបស់នាយកដ្ឋាន គឺត្រូវធ្វើឡើងដោយស្របទៅនឹងគោលការណ៍នៃច្បាប់ និងបទប្បញ្ញត្តិផ្សេងៗរបស់គ្រឹះស្ថាន ព្រមទាំងអនុលោមទៅនឹងគោលការណ៍ច្បាប់ ប្រកាស និងបទបញ្ញាតិផ្សេងៗរបស់ធនាគារជាតិ នៃកម្ពុជាផងដែរ។ មន្ត្រីសវនករត្រូវបានចាត់តាំងឱ្យធ្វើសវនកម្ម គ្រប់ការិយាល័យសាខាទាំងអស់ជារៀងរាល់ខែ ទៅលើកិច្ចការឥណទាន ហិរញ្ញវត្ថុ រដ្ឋបាល និងផ្នែកដែលពាក់ព័ន្ធផ្សេងៗទៀត ដោយស្របទៅនឹងកម្មវិធីសវនកម្មប្រចាំខែនីមួយៗ។ រាល់ចំណុចខ្វះខាតដែលបានរកឃើញ គឺមានភស្តុតាងបញ្ជាក់យ៉ាងច្បាស់លាស់ ត្រឹមត្រូវ និងគ្រប់គ្រាន់ ដែលត្រូវបានលើកឡើងយកមកជជែកពិភាក្សានៅក្នុងនាយកដ្ឋានសាមី ដើម្បីធ្វើការកែប្រែ និងផ្តល់ជាអនុសាសន៍ល្អៗ ក្នុងការកែលម្អ នៅក្នុងកម្រិតដែលអាចទទួលយកបាន។ រាល់កង្វះខាតដែលបានរកឃើញ ត្រូវបានតាមដាន និងត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់បំផុតពីនាយកដ្ឋានសវនកម្មផ្ទៃក្នុង គណៈកម្មការសវនកម្ម និងក្រុមប្រឹក្សាភិបាល។

ការទទួលខុសត្រូវរបស់នាយកដ្ឋានផ្សេងៗ ដែលបានរកឃើញថាមានកំហុស ក្នុងការអនុវត្តការងាររបស់ខ្លួន គឺត្រូវតែបញ្ចេញមតិយោបល់ទទួលស្គាល់ ឬកែប្រែកំហុស និងផ្តល់ជាអនុសាសន៍ ចេញជាផែនការសកម្មភាពទៅលើរបាយការណ៍ទាំងអស់ ដែលបានរកឃើញដោយមន្ត្រីសវនករជាន់ខ្ពស់ ទៅលើការធ្វើសវនកម្មជាក់ស្តែង បន្ទាប់មកត្រូវចម្លងជូនរបាយការណ៍នោះបន្តទៅកាន់ក្រុមប្រឹក្សាភិបាលដើម្បីធ្វើការត្រួតពិនិត្យ។

នាយកដ្ឋានសវនកម្មផ្ទៃក្នុង ត្រូវមានសមាសភាពតំណាង ក្នុងការចូលរួមប្រជុំជាប្រចាំសប្តាហ៍ នៅរៀងរាល់ថ្ងៃសុក្រ និងត្រូវធ្វើបទបង្ហាញពីរបាយការណ៍សវនកម្មរបស់ខ្លួននៅរៀងរាល់កិច្ចប្រជុំប្រចាំខែ របស់គណៈគ្រប់គ្រង។ នៅរាល់ពេលដែលមានការរកឃើញ របកគំហើញលើករណីសវនកម្មពិសេស មន្ត្រីសវនករត្រូវរាយការណ៍ភ្លាមៗ ទៅនាយកដ្ឋានសវនកម្មផ្ទៃក្នុង គណៈកម្មការសវនកម្ម និងក្រុមប្រឹក្សាភិបាល ដើម្បីធ្វើការសម្រេចចិត្តឱ្យទាន់ពេល។

## ៤.៥ ហានិភ័យ និងអនុលោមភាព

គណៈកម្មការប្រតិបត្តិតាម និងហានិភ័យ ដែលមាននាយកដ្ឋានប្រតិបត្តិតាម និងហានិភ័យ ជាសេនាធិការ នឹងមានអភិបាលឯករាជ្យ នៃសមាជិកក្រុមប្រឹក្សាភិបាល ជាប្រធានគណៈកម្មការប្រតិបត្តិតាម និងហានិភ័យ ដោយមានប្រធានមុខងារប្រតិបត្តិតាម អនុវត្តការងារ ឬការបំពេញតួនាទីរបស់ខ្លួន ប្រកបដោយឯករាជ្យភាព លើការរាយការណ៍ នូវរបាយការណ៍ជាមូលដ្ឋានគ្រឹះ ជាប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ប្រចាំពីរសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស ប្រចាំឆ្នាំ ប្រចាំពីរឆ្នាំ និងប្រចាំបីឆ្នាំ។ រាល់របាយការណ៍ទាំងអស់នឹងត្រូវធ្វើទៅតាមពេលវេលាផ្សេងៗគ្នាទៅកាន់ ធនាគារជាតិ នៃកម្ពុជា អង្គភាពស៊ើបការហិរញ្ញវត្ថុកម្ពុជា សមាគមន៍គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុកម្ពុជា ក្រុមហ៊ុនចែករំលែកព័ត៌មានឥណទានក្រេឌីតព្យូរ៉ូ (CBC) ក្រសួងពាណិជ្ជកម្ម អគ្គនាយកដ្ឋានពន្ធដារ និងរួមទាំងក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធផ្សេងទៀត ស្របតាមច្បាប់ និងបទប្បញ្ញត្តិ របស់ព្រះរាជាណាចក្រកម្ពុជា។

## ៤.៦ គោលនយោបាយ និងនីតិវិធី វិស្សលប្ល៉ូវីង

គោលនយោបាយ និងនីតិវិធី វិស្សលប្ល៉ូវីង គឺជាការពិពណ៌នាអំពីក្រុមប្រតិបត្តិសីលធម៌វិជ្ជាជីវៈ ដែលបានរៀបចំឡើងដោយ ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក ដើម្បីការពារសិទ្ធិ និងផលប្រយោជន៍របស់ អតិថិជន និយោជិត និយោជក អ្នកវិនិយោគគិន ម្ចាស់ភាគហ៊ុន និងភាគីដែលពាក់ព័ន្ធផ្សេងទៀត ដែលរងផលប៉ះពាល់នៅក្នុងដំណើរការ និងប្រតិបត្តិការអាជីវកម្មរបស់ ប៊ីអេអឹមស៊ី ។

គោលនយោបាយ និងនីតិវិធី វិស្សលប្ល៉ូវីង គឺត្រូវបានរៀបចំបង្កើតឡើងដោយ នាយកដ្ឋានប្រតិបត្តិតាម និង ហានិភ័យ នៃ ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក ដែលបានអនុម័ត ដោយអង្គប្រជុំរបស់ក្រុមប្រឹក្សាភិបាល និងភាគទុនិកចុះនៅថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៩ ក្នុងការអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់ និង មានគោលបំណងសំខាន់ៗដូចមានរៀបរាប់ជាសង្ខេប ខាងក្រោម ៖

- ធានាថានិយោជិកទាំងអស់ទទួលបានការគាំទ្រក្នុងសេចក្តីថ្លែងការណ៍ដោយមានទំនុកចិត្ត និងរាយការណ៍អំពីបញ្ហាដែលពួកគេសង្ស័យថាអាចពាក់ព័ន្ធនឹងអ្វីដែលមិនសមរម្យគ្មានក្រមសីលធម៌ និងគ្មានវិជ្ជាជីវៈ។

- លើកទឹកចិត្តដល់អ្នកប្តឹងតវ៉ាឱ្យកំណត់ និងប្រឆាំងរាល់តវិយាបទមិនសមរម្យដែលគ្មានក្រមសីលធម៌វិជ្ជាជីវៈ ដូចជាការប្រើប្រាស់ទ្រព្យសម្បត្តិមិនត្រឹមត្រូវ ឬទទួលបានអត្ថប្រយោជន៍ពីប្រតិបត្តិការអាជីវកម្មរបស់ ប៊ីអេអឹមស៊ី នៅគ្រប់កម្រិតទាំងអស់។
- ផ្តល់ក្របខណ្ឌច្បាស់លាស់សម្រាប់ការរាយការណ៍ និងការដោះស្រាយក្តីកង្វល់ទាំងអស់នេះ។
- គ្រប់គ្រងរាល់ការលាតត្រដាង ឬបណ្តឹងតវ៉ាឱ្យបានសមស្រប ទាន់ពេលវេលា និងប្រកបដោយវិជ្ជាជីវៈខ្ពស់។
- ផ្តល់ការធានាដល់ការលាតត្រដាង ឬបណ្តឹងតវ៉ាទាំងអស់ត្រូវបានយកចិត្តទុកដាក់ជាការសម្ងាត់ និងគ្រប់គ្រងដោយគ្មានការភ័យខ្លាចពីការសងសឹកគ្រប់ទម្រង់រូបភាពណាមួយឡើយ។
- ដើម្បីជួយលើកកម្ពស់ និងអភិវឌ្ឍវប្បធម៌ដោយការបើកចំហ គណនេយ្យភាព និងសុចរិតភាពរបស់ ប៊ីអេអឹមស៊ី។

បណ្តាញ និងព័ត៌មានសំខាន់ៗ នៃវិស្សលប្លូវឹង ដែលអ្នកប្តឹងតវ៉ាអាចលើកឡើងពីការព្រួយបារម្ភរបស់ពួកគេបានតាមរយៈការនិយាយដោយផ្ទាល់មាត់ ការសរសេរជាលាយលក្ខណ៍អក្សរ និងភាពអនាមិក នៅក្នុងទំរង់ផ្លូវការដែលមានទាំងលើក្រដាស និងប្រព័ន្ធអេឡិកត្រូនិក ដែលបានដាក់ចេញឱ្យអនុវត្ត ក្នុងការប្តឹងតវ៉ាប្រកបដោយទំនុកចិត្ត និងការរក្សាបានការសម្ងាត់ខ្ពស់។ ទោះជាយ៉ាងណាក៏ដោយ ចំពោះការប្តឹងតវ៉ាដែលសរសេរជាលាយលក្ខណ៍អក្សរ ក្នុងទំរង់ផ្លូវការ ប៊ីអេអឹមស៊ី វិស្សលប្លូវឹង គឺត្រូវបានលើកទឹកចិត្តក្នុងការប្តឹងតវ៉ា ជាជាងការប្តឹង ឬការលើកឡើងដោយការនិយាយដោយផ្ទាល់មាត់ផងដែរ ដើម្បីបញ្ជូនទៅកាន់នាយកដ្ឋានហានិភ័យ និងប្រតិបត្តិតាម ដែលជាអ្នកទទួលបន្ទុកក្នុងការអនុវត្ត ប្រកបដោយប្រសិទ្ធភាព និងឯករាជ្យភាព តាមរយៈការសរសេរជាលាយលក្ខណ៍អក្សរ នៅក្នុងទំរង់ជាផ្លូវការ ប៊ីអេអឹមស៊ី វិស្សលប្លូវឹង ដាក់ចូលក្នុងប្រអប់សម្ងាត់ និងតាមរយៈគេហទំព័រ ឬតាមសារអេឡិកត្រូនិក អ៊ីម៉ែល របស់ ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក ដើម្បីធ្វើការត្រួតពិនិត្យ និងទទួលយក ដែលរួមមានដូចខាងក្រោម ៖

| មុខងារទទួលបន្ទុក | លេខទំនាក់ទំនង |
|---|---|
| - នាយកដ្ឋានហានិភ័យ និងប្រតិបត្តិតាម | ០៧០ ៥៥៥ ០៨១/ rc.dept@bamc.com.kh |

## ៤.៧ ក្របខ័ណ្ឌការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក បានរៀបចំចងក្រងនូវគោលនយោបាយ និងនីតិវិធី ស្តីពី ការអនុវត្តកាតព្វកិច្ច នៃការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឱ្យស្របតាមច្បាប់ និងបទប្បញ្ញត្តិ របស់ព្រះរាជាណាចក្រកម្ពុជាជាធរមាន។

គោលនយោបាយ និងនីតិវិធី ស្តីពី ការអនុវត្តកាតព្វកិច្ច នៃការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ត្រូវបានធ្វើវិសោធនកម្ម និងអនុម័តសម្រេច ឱ្យប្រើប្រាស់ជាផ្លូវការ ដោយក្រុមប្រឹក្សាភិបាល និងភាគទុនិក នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២០។ លើសពីនេះទៀត គ្រឹះស្ថានក៏បានដាក់ចេញនូវគោលការណ៍ណែនាំបន្ថែម ស្តីពី វិធានការយកចិត្តទុកដាក់ស្គាល់អតិថិជន (CDD) ការស្គាល់ អតិថិជន (KYC) ការប្រឆាំងការសម្អាតប្រាក់ (AML) និងហិរញ្ញប្បទានភេរវកម្ម (CFT) ដែលត្រូវបានអនុម័តសម្រេចដាក់ឱ្យប្រើប្រាស់ជាផ្លូវការដោយប្រធាននាយកប្រតិបត្តិ នៅថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០ ដើម្បីអាចជួយបំពេញបន្ថែមលើគោលនយោបាយ និងនីតិវិធី ស្តីពីការអនុវត្តកាតព្វកិច្ចនៃការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្មឱ្យកាន់តែទទួលបានប្រសិទ្ធិភាព និងប្រសិទ្ធិផលខ្ពស់ ក្នុងរង្វង់គ្រឹះស្ថាន ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក ស្របតាមច្បាប់ ដែលបានធ្វើបច្ចុប្បន្នកម្មថ្មីរបស់ជាតិ។

## ៥ សម្រង់របាយការណ៍ហិរញ្ញវត្ថុក្រោយសវនកម្មឆ្នាំ២០២២

### ៥.១ របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល សូមធ្វើការដាក់ជូននូវរបាយការណ៍របស់ខ្លួនដោយភ្ជាប់ជាមួយនឹងរបាយការណ៍ហិរញ្ញវត្ថុរបស់ ប៊ីអេអឹមស៊ី ហ្វាយនែន ម.ក ហៅកាត់ថា ("ក្រុមហ៊ុន") ដែលបានធ្វើសវនកម្មរួចសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ ២០២២។

**សកម្មភាពចម្បង**

សកម្មភាពចម្បងរបស់ក្រុមហ៊ុន គឺផ្តល់សេវាកម្មមីក្រូហិរញ្ញវត្ថុ ដែលប្រកបដោយនិរន្តភាពចំពោះសហគ្រាសធុនតូច និងមធ្យម និងគ្រួសារដែលមានចំណូលទាបនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ ពុំមានការប្រែប្រួលជាសារវន្តទៅលើសកម្មភាពចម្បងនៅក្នុងការិយបរិច្ឆេទនេះទេ។

**លទ្ធផលហិរញ្ញវត្ថុ**

លទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមានដូចខាងក្រោមៈ

| | | | (កំណត់ឡើងវិញ) | |
|---|---|---|---|---|
| | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | | ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | |
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) |
| ប្រាក់(ខាត)/ចំណេញមុនដកពន្ធ | (៣១៦,៣៣៩) | (១,២៩២,៨៧៨) | ៤៤,៧៨៣ | ១៨៣,១៧៨ |
| ចំណាយពន្ធលើប្រាក់ចំណេញ | - | - | (៦៦,៧៧៧) | (២៧១,៦៤៩) |
| ប្រាក់ខាតសុទ្ធសម្រាប់ការិយបរិច្ឆេទ | (៣១៦,៣៣៩) | (១,២៩២,៨៧៨) | (២១,៩៩៤) | (៨៩,៤៧១) |

**ភាគលាភ**

ពុំមានភាគលាភណាត្រូវបានប្រកាស ឬត្រូវបានបង់ ហើយក្រុមប្រឹក្សាភិបាលក៏ពុំបានផ្តល់ជាអនុសាសន៍ឱ្យមានការបែងចែកភាគលាភសម្រាប់ការិយបរិច្ឆេទនោះទេ។

**ដើមទុន**

| នាថ្ងៃទីខែមករា 1 | ១០,៥០០ | ៤២,៧៧៧ | ១០,៥០០ | ៤២,៤៧៣ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | ៤៥២ | - | ៣០៤ |
| នាថ្ងៃចុងការិយបរិច្ឆេទ | ១០,៥០០ | ៤៣,២២៩ | ១០,៥០០ | ៤២,៧៧៧ |
| ដកៈ **រំលស់បង្គរ** | | | | |
| នាថ្ងៃទី ខែ មករា 1 | ៧,២៩៣ | ២៩,៧១២ | ៦,២៤២ | ២៥,២៤៩ |
| រំលស់ក្នុងការិយបរិច្ឆេទ | ១,០៥០ | ៤,២៩២ | ១,០៥១ | ៤,២៧៥ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | ៣៤៥ | - | ១៨៨ |
| នាថ្ងៃចុងការិយបរិច្ឆេទ | ៨,៣៤៣ | ៣៤,៣៤៩ | ៧,២៩៣ | ២៩,៧១២ |
| **តម្លៃយោង** | | | | |
| នាថ្ងៃចុងការិយបរិច្ឆេទ | ២,១៥៧ | ៨,៨៨០ | ៣,២០៧ | ១,៣០៦៥ |

## ១១ ប្រាក់កម្ចី

| | ២០២២ | | ២០២១ (កំណត់ឡើងវិញ) | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) |
| លោក ហ៊ុន ពេជ្រ ជាប្រធានក្រុមប្រឹក្សាភិបាល (កំណត់សម្គាល់១៩ ២) | ១,០៧៥,៦០២ | ៤,៤២៨,២៥៣ | ១,០៦៣,៣០០ | ៤,៣៣១,៨៨៤ |
| ការប្រាក់បង្គរ | ២១៣,៤០៧ | ៨៧៨,៥៩៧ | ១៤៧,៩៥៦ | ៦០២,៧៧៣ |
| | ១,២៨៩,០០៩ | ៥,៣០៦,៨៥០ | ១,២១១,២៥៦ | ៤,៩៣៤,៦៥៧ |

## ១២ ចំណូលផ្សេងៗ

| | ២០២២ | ២០២១ (កំណត់ឡើងវិញ) |
|---|---|---|

| | | | ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) |
| ចំណាយបង្គរ | ៥,៧៩៨ | ២៣,៨៧០ | ១១,៦២២ | ៤៧,៣៤៨ |
| បំណុលពន្ធផ្សេងៗ | ៥,៦៥៥ | ២៣,២៨២ | ៣,៨៦២ | ១៥,៧៣៤ |
| ផ្សេងៗ | ២៨៩ | ១,១៩០ | ៣៣ | ១៣៤ |
| | ១១,៧៤២ | ៤៨,៣៤២ | ១៥,៥១៧ | ៦៣,២១៦ |

# ១៣ ពន្ធលើប្រាក់ចំណេញ

## ១៣ ១ ពន្ធពន្យារជាបំណុល

ពន្ធពន្យារជាទ្រព្យសកម្ម និងជាបំណុល គឺត្រូវបានកាត់កងទៅនៅពេលដែលមានសិទ្ធិស្របច្បាប់ដើម្បីកាត់កងពន្ធជាទ្រព្យសកម្ម ជាមួយនឹងបំណុលពន្ធ ហើយនិងនៅពេលដែលពន្ធពន្យារទាក់ទងទៅនឹងអាជ្ញាធរពន្ធដារ ដូចគ្នា។ ចំនួនទឹកប្រាក់ខាងក្រោមដែលត្រូវបានកំណត់បន្ទាប់ពីកាត់កងសមស្រប ត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ៖

| | ២០២២ | | ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) |
| ពន្ធពន្យារជាទ្រព្យសកម្ម | - | - | - | - |
| ពន្ធពន្យារជាបំណុល | ៧៤៥ | ៣,០៦៧ | ៧៤៥ | ៣,០៣៥ |
| | ៧៤៥ | ៣,០៦៧ | ៧៤៥ | ៣,០៣៥ |

(ក) ការប្រែប្រួលពន្ធពន្យារជាបំណុលក្នុងឆ្នាំមានដូចខាងក្រោម៖

| | ២០២២ | | ២០២១ (កំណត់ឡើងវិញ) | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) |
| នាថ្ងៃទី ១ ខែ មករា | ៧៤៥ | ៣,០៣៥ | ៧៤៥ | ៣,០១៤ |
| ទទួលស្គាល់ក្នុងចំណេញ ឬខាត | - | - | - | - |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | ៣២ | - | ២១ |
| នាថ្ងៃចុងការិយបរិច្ឆេទ | ៧៤៥ | ៣,០៦៧ | ៧៤៥ | ៣,០៣៥ |

(ខ) ពន្ធពន្យារជាបំណុលបានមកពីឯកតាដូចខាងក្រោម៖

| | ២០២២ | | ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) |
| រំលស់ | ៧៤៥ | ៣,០៦៧ | ៧៤៥ | ៣,០៣៥ |
| សំវិធានធនលើការខាតបង់លើឱនភាពនៃតម្លៃ | - | - | - | - |
| | ៧៤៥ | ៣,០៦៧ | ៧៤៥ | ៣,០៣៥ |

## ១៣ ២ បំណុលពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ

| | ២០២២ | | ២០២១ (កំណត់ឡើងវិញ) | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) |
| នាថ្ងៃទី១ ខែមករា | ៣៣,៥២១ | ១៣៦,៥៦៥ | ៦៧១ | ២,៧១៤ |
| ចំណាយពន្ធអប្បរមា/ពន្ធលើប្រាក់ចំណេញ | ៧៤០១ | ៣០,២៤៨ | ៦៦,៧៧៧ | ២៧១,៦៤៩ |
| ពន្ធអប្បរមា/ពន្ធលើប្រាក់ចំណេញដែលបានបង់ | (៤០,៩២២) | (១៦៧,២៤៨) | (៣៣,៩២៧) | (១៣៨,០១៥) |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | - | ៤៣៥ | - | ២១៧ |
| នាថ្ងៃចុងការិយបរិច្ឆេទ | - | - | ៣៣,៥២១ | ១៣៦,៥៦៥ |

## ១៣ ៣ ចំណាយពន្ធលើប្រាក់ចំណេញ

អនុលោមទៅតាមច្បាប់សារពើពន្ធនៃព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនមានកាតព្វកិច្ចបង់ពន្ធលើប្រាក់ចំណេញដោយគណនាតាមអត្រា 20% នៃប្រាក់ចំណេញជាប់ពន្ធ ឬក៏បង់ពន្ធអប្បបរមាដោយគណនាតាមអត្រា 1% នៃប្រាក់ចំណូលសរុប នៅពេលដែលពន្ធមួយណាមានចំនួនច្រើនជាង។

| | ២០២២ | | ២០២១ (កំណត់ឡើងវិញ) | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) |
| បំណុលពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ | - | - | ៤១,១០៥ | ១៦៧,២១៥ |
| ពន្ធពន្យារ | - | - | - | - |
| សំវិធានធនខ្វះនៃពន្ធលើប្រាក់ចំណេញក្នុងការិយបរិច្ឆេទមុន | - | - | | |
| ពន្ធលើប្រាក់ចំណេញ | - | - | ២៥,៦៧២ | ១០៤,៤៣៤ |

ការផ្ទៀងផ្ទាត់ចំណាយពន្ធលើប្រាក់ចំណេញ ដែលគណនាតាមអត្រាពន្ធជាផ្លូវការធៀបទៅនឹងពន្ធលើប្រាក់ចំណេញដែលបង្ហាញក្នុងចំណេញ ឬខាតមានដូចខាងក្រោម៖

| | ២០២២ | | ២០២១ | (កំណត់ឡើងវិញ) |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** (កំណត់សម្គាល់២.៤) | **ដុល្លារអាមេរិក** | **ពាន់រៀល** (កំណត់សម្គាល់២.៤) |
| ប្រាក់(ខាត)/ចំណេញមុនដកពន្ធ | (៣១៦,៣៣៩) | (១,២៩២,៨៧៨) | ៤៤,៧៨៣ | ១៨២,១៧៨ |
| ពន្ធលើប្រាក់ចំណេញផ្អែកតាមអត្រាពន្ធផ្លូវការ ២០% | (៦៣,២៦៨) | (២៥៨,៥៧៦) | ៨,៩៥៧ | ៣៦,៤៣៦ |
| *ផលប៉ះពាល់ពន្ធទាក់ទងនឹង៖* | | | | |
| ចំណាយមិនអាចកាត់កងបាន | ៧,៥២២ | ៣០,៧៤២ | ៣២,១៤៨ | ១៣០,៧៧៨ |
| ភាពលម្អៀងបណ្ដោះអាសន្ន | ១៧,៧១៧ | ៧២,៤០៩ | - | - |
| សំវិធានធនខ្វះនៃពន្ធលើប្រាក់ចំណេញក្នុងការិយបរិច្ឆេទមុន | | | | |
| ពន្ធពន្យារជាទ្រព្យសកម្មមិនទាន់ទទួលស្គាល់ | - | - | ២៥,៦៧២ | ១០៤,៤៣៤ |
| | ៣៨,០២៩ | ១៥៥,៤២៥ | | |

ការគណនានៃការចំណាយពន្ធលើប្រាក់ចំណេញនេះ គឺជាប្រធានបទក្នុងការពិនិត្យ និងការវាយតម្លៃចុងក្រោយរបស់អាជ្ញាធរពន្ធ។

# ១៤ ដើមទុន និង ដើមទុនបន្ថែម

## ១៤ ១ ដើមទុន

| | ២០២២ | | | ២០២១ | | |
|---|---|---|---|---|---|---|
| | ចំនួន | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) | ចំនួន | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) |
| បានចុះបញ្ជី៖ | | | | | | |
| ភាគហ៊ុនធម្មតាតម្លៃ១០ ដុល្លារអាមេរិកក្នុងមួយហ៊ុន) | ៣៥០,០០០ | ៣,៥០០,០០០ | ១៤,០០០,០០០ | ៣៥០,០០០ | ៣,៥០០,០០០ | ១៤,០០០,០០០ |
| ចុះបញ្ជី និងបោះផ្សាយ៖ | | | | | | |
| ភាគហ៊ុនធម្មតាតម្លៃ១០ ដុល្លារអាមេរិកក្នុងមួយហ៊ុន) | ៣៥០,០០០ | ៣,៥០០,០០០ | ១៤,០០០,០០០ | ៣៥០,០០០ | ៣,៥០០,០០០ | ១៤,០០០,០០០ |

ចំនួនភាគហ៊ុនរបស់ក្រុមហ៊ុន និងរចនាសម្ព័ន្ធភាគហ៊ុនមានដូចខាងក្រោម៖

| | ២០២២ | | | ២០២១ | | |
|---|---|---|---|---|---|---|
| | ភាគរយនៃភាគហ៊ុនកាន់កាប់ | ចំនួនភាគហ៊ុន | ចំនួនដុល្លារអាមេរិក | ភាគរយនៃភាគហ៊ុនកាន់កាប់ | ចំនួនភាគហ៊ុន | ចំនួនដុល្លារអាមេរិក |
| Peanut Cambo Corporation Ltd | ៩៧ ៨១% | ៣៤២,៣៥០ | ៣,៤២៣,៥០០ | ១ | ៣៤២,៣៥០ | ៣,៤២៣,៥០០ |
| លោក Kang Dong Hyun | ២ ១៩% | ៧,៦៥០ | ៧៦,៥០០ | ០ | ៧,៦៥០ | ៧៦,៥០០ |
| | ១០០% | ៣៥០,០០០ | ៣,៥០០,០០០ | ១ | ៣៥០,០០០ | ៣,៥០០,០០០ |

## ១៤ ២ ដើមទុនបន្ថែម

ការដាក់មូលធនបន្ថែមកើតឡើងដោយផលប៉ះពាល់ពីប្រាក់កម្ចីពីភាគទុននិកដែលអត្រាការប្រាក់ទាបជាងទីផ្សារ។

## ១៥ ទុនបម្រុងតាមបទប្បញ្ញត្តិ

ទុនបម្រុងតាមបទប្បញ្ញត្តិ តំណាងឱ្យភាពខុសគ្នានៃសំវិធានធនរវាងឱនភាពនៃតម្លៃលើឥណទានស្របតាម CIFRS និងសំវិធានធនតាមបទប្បញ្ញត្តិដោយអនុលោមតាមបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា។

ការផ្ទេរពីប្រាក់ចំណេញរក្សាទុកទៅទុនបម្រុង ត្រូវបានធ្វើឡើងនៅពេលដែលសំវិធានធនតាមបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា ខ្ពស់ជាងសំវិធានធនតាម CIFRS for SMEs៖

| | | | | (កំណត់ឡើងវិញ) |
|---|---|---|---|---|
| | ២០២២ | | ២០២១ | |
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់ ២.៤) |
| នាថ្ងៃទី ១ ខែ មករា | - | - | - | - |
| សំវិធានធនលើឱនភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុតាមបទប្បញ្ញត្តិរបស់ធនាគារជាតិនៃកម្ពុជា | | | | |
| - ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារ ផ្សេងៗ | ១,០៩៣ | ៤,៥០១ | ៣,៨៧៩ | ១៥,៨០៤ |
| - ឥណទានផ្តល់ដល់អតិថិជន | ៨២,៦១៤ | ៣៤០,១២២ | ៩៥,៨២១ | ៣៩០,៣៧៥ |
| | ៨៣,៧០៧ | ៣៤៤,៦២៣ | ៩៩,៧០០ | ៤០៦,១៧៩ |
| សំវិធានធនលើឱនភាពនៃទ្រព្យសកម្មហិរញ្ញវត្ថុតាម CIFRS for SMEs (កំណត់សម្គាល់ ៧) | ៧៩,៥៩៩ | ៣២៧,៧១០ | ១៤៨,៤៤៧ | ៦០៤,៧៧៣ |
| នាថ្ងៃចុងការិយបរិច្ឆេទ | ៤,១០៨ | ១៦,៩១៣ | - | - |

## ១៦ ចំណូលពីការប្រាក់

| | | | | (កំណត់ឡើងវិញ) |
|---|---|---|---|---|
| | ២០២២ | | ២០២១ | |
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) |
| ឥណទានផ្តល់ដល់អតិថិជន | ៥៣១,៩៦៩ | ២,១៧៤,១៥៧ | ៦១២,៤៥៥ | ២,៤៩១,៤៦៧ |

## ១៧ ចំណាយទូទៅ និងរដ្ឋបាល

| | ២០២២ | | (កំណត់ឡើងវិញ) ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) |
| ប្រាក់បៀវត្សន៍ និងចំណាយពាក់ព័ន្ធ | ២៨៧,០០៨ | ១,១៧៣,០០២ | ៣២២,៥៨៨ | ១,៣១២,២៨៨ |
| ការលុបចោលឥណទាន | ៤០៨,៧៣៨ | ១,៦៧០,៥១២ | - | - |
| ចំណាយលើការជួល | ៨១,៦១២ | ៣៣៣,៥៤៨ | ៧៨,២៥៩ | ៣១៨,៣៥៨ |
| កម្រៃសេវាវិជ្ជាជីវៈ និងផ្នែកច្បាប់ | ៦៤,២០៧ | ២៦២,៤១៤ | ៤៤,៧៦៨ | ១៨២,១១៦ |
| ចំណាយលើសេវាសន្តិសុខ | ១៧,៤២៤ | ៧១,២១២ | ១៧,៤២៤ | ៧០,៨៨១ |
| ថ្លៃទឹក និងថ្លៃភ្លើង | ១០,៦៨៦ | ៤៣,៦៧៤ | ១០,៨៦០ | ៤៤,១៧៨ |
| ចំណាយប្រតិបត្តិការយានយន្ត | ១០,៥១៤ | ៤២,៩៧១ | ៦,១២១ | ២៤,៩០០ |
| ចំណាយទំនាក់ទំនង | ៧,៩៨០ | ៣២,៦១៤ | ៦,៧១៥ | ២៧,៣១៧ |
| ចំណាយលើការជួសជុល | ៧,៣៣១ | ២៩,៩៦២ | ៥,៨៥៧ | ២៣,៨២៦ |
| ចំណាយលើសមាជិកភាព | ៤,៣១០ | ១៧,៦១៥ | ៤,៦៨៦ | ១៩,០៦៣ |
| ចំណាយលើសម្ភារៈការិយាល័យ | ៣,៥៨៣ | ១៤,៦៤៤ | ៦,០៤៥ | ២៤,៥៩១ |
| ការបង់ពិន័យ | ១,៨៤៣ | ៧,៥៣២ | ៨៧០ | ៣,៥៣៩ |
| ចំណាយលើការធ្វើដំណើរ | ៣២០ | ១,៣០៨ | ២,០២៨ | ៨,២៥០ |
| ចំណាយលើទីផ្សារ និងការផ្សព្វផ្សាយ | ២៧៩ | ១,១៤០ | ១៨០ | ៧៣២ |
| ផ្សេងៗ | ៥០,៥៦៤ | ២០៦,៦៥៥ | ៥០,៩០០ | ២០៧,០៦១ |
| | ៩៥៦,៣៩៩ | ៣,៩០៨,៨០៣ | ៥៥៧,៣០១ | ២,២៦៧,១០០ |

## ១៨ សាច់ប្រាក់ និងសាច់ប្រាក់សមមូល

| | ២០២២ | | ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) |
| សាច់ប្រាក់ក្នុងដៃ (កំណត់សម្គាល់ ៤) | ៨,៩៩៩ | ៣៦,៦៣៧ | ១១,៩៥៨ | ៤៨,៧១៧ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា (កំណត់សម្គាល់ ៥) | ២,០៣៦ | ៨,៣៨២ | ១,៩៨០ | ៨,០៦៧ |
| ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារផ្សេងៗ (ជាមួយរយៈពេលកំណត់ ឬស្មើ ៣ ខែ) (កំណត់សម្គាល់ ៦) | ១០៩,២៩០ | ៤៤៩,៩៤៧ | ៣៨៧,៩២៣ | ១៥៨០,៣៩៨ |
| | ១២០,២២៥ | ៤៩៤,៩៦៦ | ៤០១,៨៦១ | ១,៦៣៧,១៨២ |

## ១៩ ប្រតិបត្តិការ និងសមតុល្យជាមួយសម្ព័ន្ធញាតិ

### ១៩ ១ ប្រតិបត្តិការជាមួយសម្ព័ន្ធញាតិ

| | ២០២២ | | ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) |
| លោក ហ៊ុន ពេជ្រ ជាប្រធានក្រុមប្រឹក្សាភិបាល | | | | |
| ការដកប្រាក់កម្ចី | - | - | ១១,២២៣ | ៤៥,៦៥៥ |
| ចំណាយលើការប្រាក់ | ៨៩,៣០២ | ៣៦៤,៩៧៧ | ៨៨,២២៣ | ៣៥៨,៨៩១ |
| | | | | |
| កម្រៃសម្រាប់អ្នកគ្រប់គ្រងសំខាន់ៗ៖ | | | | |
| ចំណាយសម្រាប់នាយក និងអ្នកគ្រប់គ្រងសំខាន់ៗ | ៣០,០០០ | ១២២,៦១០ | ៤០,៦៨៨ | ១៦៥,៥១៩ |

## ១៩ ២ សមតុល្យជាមួយនឹងសម្ព័ន្ធញាតិ

| | ២០២២ | | ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) |
| លោក ហ៊ុន ពេជ្រ ជាប្រធានក្រុមប្រឹក្សាភិបាល (*) | | | | |
| ប្រាក់កម្ចី | ១,០៧៥,៦០២ | ៤,៤២៨,២៥៣ | ១,០៦៣,៣០០ | ៤,៣៣១,៨៨៤ |
| ការប្រាក់ដែលត្រូវបង់ | ២១៣,៤០៧ | ៨៧៨,៥៩៧ | ១៤៧,៩៥៦ | ៦០២,៧៧៣ |
| | ១,២៨៩,០០៩ | ៥,៣០៦,៨៥០ | ១,២១១,២៥៦ | ៤,៩៣៤,៦៥៧ |
| ឥណទានផ្តល់ឱ្យបុគ្គលិក | ៥៥០,៤៥៧ | ២,២៦៦,២៣១ | ៤៩៦,០០៩ | ២,០២០,៧៤២ |

(*) ប្រាក់កម្ចីពីលោក ហ៊ុន ពេជ្រ ជាប្រធានក្រុមប្រឹក្សាភិបាល ជាការខ្ចីប្រាក់មិនមានការធានា ហើយមានការប្រាក់ក្នុងអត្រា 7% ក្នុងមួយឆ្នាំ (២០២១: ៧%) ហើយត្រូវបង់ក្នុងរយៈពេល ៤ឆ្នាំ។

# ២០ ភតិសន្យាជួល

ក្រុមហ៊ុនមានភតិសន្យាលើការជួលការិយាល័យជាមួយការសន្យាជួលអប្បបរមាដូចខាងក្រោម៖

| | ២០២២ | | ២០២១ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) |
| តិចជាង ១ ឆ្នាំ | ៥៤,៦៦៧ | ២២៥,០៦៣ | ៦៤,៦៦៧ | ២៦៣,៤៥៣ |
| ចាប់ពី ២ ឆ្នាំ ដល់ ៥ ឆ្នាំ | ១៩,៤៤៤ | ៨០,០៥៣ | ៧៥,១១១ | ៣០៦,០០២ |
| | ៧៤,១១១ | ៣០៥,១១៦ | ១៣៩,៧៧៨ | ៥៦៩,៤៥៥ |

## ២១ ពន្ធដាយថាហេតុ

ពន្ធស្ថិតនៅក្រោមការត្រួតពិនិត្យ និងតាមដានអង្កេតដោយអាជ្ញាធរដែលផ្តល់សិទ្ធិដោយច្បាប់ក្នុងការដាក់ពិន័យ ដាក់ទណ្ឌកម្ម និងការគិតការប្រាក់។ ការអនុវត្តច្បាប់ និងបទប្បញ្ញត្តិពន្ធលើប្រតិបត្តិការច្រើនប្រភេទប្រឈមនឹងការបកស្រាយផ្សេងៗគ្នា។

បញ្ហាទាំងនេះ អាចបង្កើតឱ្យមានហានិភ័យពន្ធនៅក្នុងព្រះរាជាណាចក្រកម្ពុជាដែលមានលក្ខណៈធំជាងនៅប្រទេសដទៃទៀត។ អ្នកគ្រប់គ្រងជឿជាក់ថា ការធ្វើសំវិធានធនមានលក្ខណៈគ្រប់គ្រាន់ដោយផ្អែកលើការ បកស្រាយនៃនីតិកម្មពន្ធ។ ក៏ប៉ុន្តែអាជ្ញាធរជាប់ពាក់ព័ន្ធអាចនឹងមានការបកស្រាយខុសៗគ្នា ហើយផលប៉ះពាល់អាចមានទំហំធំ។

## ២២ គោលនយោបាយគណនេយ្យសំខាន់ៗ

### ២២ ១ មូលដ្ឋាននៃការសរុបរួម

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន រួមមានរបាយការណ៍ហិរញ្ញវត្ថុរបស់ទីស្នាក់ការកណ្តាល និងសាខារបស់ ខ្លួន។ រាល់សមតុល្យ និងប្រតិបត្តិការអន្តរសាខាទាំងអស់ត្រូវបានលុបបំបាត់ចោល។

### ២២ ២ សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សាច់ប្រាក់ និងសាច់ប្រាក់សមមូល រួមមានសាច់ប្រាក់ក្នុងដៃ និងសមតុល្យធនាគារ និងប្រាក់បញ្ញើនៅធនាគារដែលមានកាលវសាន្តនៅពេលតម្កល់ដំបូងមានរយៈពេល 3ខែ ឬតិចជាង និងការវិនិយោគរយៈពេលខ្លីដែលអាចប្តូរជាសាច់ប្រាក់ពេលណាក៏បាន ដោយមានហានិភ័យតិចតួចចំពោះការផ្លាស់ប្តូរតម្លៃ។

សាច់ប្រាក់ និងសាច់ប្រាក់សមមូលត្រូវបានកត់ត្រាតាមរំលស់ថ្លៃដើម ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាពនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

### ២២ ៣ ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារផ្សេងៗ

ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារត្រូវបានកត់ត្រាតាមរំលស់ថ្លៃដើមដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាពនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

### ២២ ៤ ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា

ប្រាក់បញ្ញើ និងប្រាក់តម្កល់នៅធនាគារជាតិនៃកម្ពុជា ដែលរួមបញ្ចូលទាំងប្រាក់តម្កល់ធានាដើមទុនត្រូវបាន កត់ត្រាតាមរំលស់ថ្លៃដើមដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។

ប្រាក់តម្កល់ធានាដើមទុន ត្រូវបានរក្សាទុកស្របតាមច្បាប់កម្ពុជាស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុហើយត្រូវបានកំណត់ដោយភាគរយនៃដើមទុនអប្បបរមាដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា។ ប្រាក់តម្កល់ធានា ដើមទុនមិនអាចផ្តល់ហិរញ្ញប្បទានដល់ប្រតិបត្តិការប្រចាំថ្ងៃរបស់ក្រុមហ៊ុនទេ ហេតុដូច្នេះមិនត្រូវបានចាត់ទុកថាជាផ្នែកមួយនៃសាច់ប្រាក់ និងសមមូលសាច់ប្រាក់សម្រាប់បង្ហាញក្នុងរបាយការណ៍លំហូរសាច់ប្រាក់ឡើយ។

### ២២ ៥ ឥណទានផ្តល់ដល់អតិថិជន

ឥណទានផ្តល់ដល់អតិថិជន គឺជាទ្រព្យសកម្មហិរញ្ញវត្ថុអនិសន្ទស្សដែលការទូទាត់មានលក្ខណៈថេរ ឬអាចកំណត់បានដែលមិនមានសម្រង់តម្លៃក្នុងទីផ្សារសកម្ម ហើយក្រុមហ៊ុនមិនមានបំណងលក់ភ្លាមៗ ឬក្នុង រយៈពេលខ្លីណាមួយនោះទេ។

ឥណទានផ្តល់ដល់អតិថិជន ត្រូវបានគណនាតាមតម្លៃសមស្រប បូកនឹងការចំណាយប្រតិបត្តិការផ្ទាល់ ហើយត្រូវបានគណនាជាបន្តបន្ទាប់គិតតាមរំលស់ថ្លៃដើម ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាព។

### ២២ ៦ ទ្រព្យសកម្មផ្សេងៗ

ទ្រព្យសកម្មផ្សេងៗ ត្រូវបានកត់ត្រាតាមតាមរំលស់ថ្លៃដើមដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាពនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

## ២២ ៧ ទ្រព្យ និងបរិក្ខារ

*(ក)* *ការទទួលស្គាល់ និងការវាស់វែង*

ផ្នែកទ្រព្យ និងបរិក្ខារត្រូវបានកត់ត្រាតាមវិធីសាស្ត្រថ្លៃដើម ដករំលស់បង្គរ និងការខាតបង់លើឱនភាពនៃតម្លៃបង្គរប្រសិនបើមាន។

នៅពេលផ្នែកនៃទ្រព្យ និងបរិក្ខារមានអាយុកាលប្រើប្រាស់ខុសៗគ្នាធាតុទាំងនោះត្រូវបានគេចាត់ទុកជាផ្នែក ផ្សេងៗ (សមាសធាតុចម្បងៗ)នៃទ្រព្យ និងបរិក្ខារ។

ចំណេញ ឬខាតលើការលក់ចេញនៃទ្រព្យ និងបរិក្ខារណាមួយត្រូវបានកំណត់ដោយភាពខុសគ្នារវាងសាច់ប្រាក់ទទួលពីការលក់ និងតម្លៃយោងនៃផ្នែកនោះ ហើយត្រូវបានទទួលស្គាល់ជាប្រាក់ចំណេញផ្សេងៗនៅក្នុង របាយការណ៍ចំណេញ ឬខាត។

*(ខ)* *ការចំណាយបន្ទាប់*

ថ្លៃដើមនៃការផ្លាស់ប្តូរធាតុមួយនៃទ្រព្យ និងបរិក្ខារដែលបានទទួលស្គាល់រួចមកហើយត្រូវបានបូកបញ្ចូលនៅក្នុងតម្លៃយោងនៃផ្នែកនោះ ប្រសិនបើវាអាចមានលទ្ធភាពផ្តល់នូវអត្ថប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគតដល់ ក្រុមហ៊ុន ហើយតម្លៃរបស់វាអាចវាស់វែងបានដោយភាពជឿជាក់។ តម្លៃយោងនៃធាតុដែលបានជំនួសនោះត្រូវបានលុបចោល។ រាល់ចំណាយក្នុងការថែទាំប្រចាំថ្ងៃផ្សេងៗ ត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ចំណេញ ឬខាតក្នុងការិយបរិច្ឆេទដែលបានកើតឡើង។

*(គ)* *រំលស់*

រំលស់ ត្រូវបានគណនា និងបែងចែកថ្លៃដើមនៃទ្រព្យសកម្មដកតម្លៃដែលនៅសល់ ទៅតាមអាយុកាលប្រើប្រាស់ប៉ាន់ស្មាននៃទ្រព្យសកម្មនីមួយៗ។ រំលស់ចាប់ផ្តើមគណនានៅពេលដែលទ្រព្យសកម្មអាចប្រើប្រាស់បាន។ ចំពោះវិធីសាស្ត្ររំលស់ និងអាយុកាលប្រើប្រាស់នៃទ្រព្យ និងបរិក្ខារមានដូចខាងក្រោម៖

| | | |
|---|---|---|
| ការកែលំអរអគារជួល | ៥ ឆ្នាំ | វិធីសាស្ត្រនៃការរំលស់ស្មើភាគ |
| គ្រឿងសង្ហារឹម និងគ្រឿងបំពាក់ | ៥ ឆ្នាំ | វិធីសាស្ត្រនៃការរំលស់ស្មើភាគ |
| បរិក្ខារកុំព្យូទ័រ | ៥ ឆ្នាំ | វិធីសាស្ត្រនៃការរំលស់ស្មើភាគ |
| បរិក្ខារការិយាល័យ និងបរិក្ខារផ្សេងៗ | ៥ ឆ្នាំ | វិធីសាស្ត្រនៃការរំលស់ស្មើភាគ |
| យានយន្ត | ៥ ឆ្នាំ | វិធីសាស្ត្រនៃការរំលស់ស្មើភាគ |
| ទ្រព្យសម្បត្តិផ្សេងៗ | ៥ ឆ្នាំ | វិធីសាស្ត្រនៃការរំលស់ស្មើភាគ |

ប្រសិនបើមានការកែប្រែជាសារវន្តទៅលើអត្រារំលស់ អាយុកាលប្រើប្រាស់ តម្លៃនៅសល់នៃទ្រព្យ និងបរិក្ខារនោះរំលស់ត្រូវបានកំណត់ឡើងវិញដើម្បីឆ្លុះបញ្ចាំងនូវការប៉ាន់ស្មានថ្មី។

ទ្រព្យ និងបរិក្ខារដែលបានធ្វើរំលស់អស់ គឺត្រូវបានកត់ត្រាក្នុងរបាយការណ៍ហិរញ្ញវត្ថុរហូតដល់លក់ចេញ ឬលុបចោល។

## ២២ ៨ ទ្រព្យសកម្មអរូបី

ទ្រព្យសកម្មអរូបី រួមមានអាជ្ញាប័ណ្ណកម្មវិធីកុំព្យូទ័រ និងថ្លៃដើមដែលជាប់ទាក់ទង ត្រូវបានកំណត់ដោយតម្លៃដើម ដករំលស់បង្គរ និងឱនភាពនៃតម្លៃបង្គរប្រសិនបើមាន។

ទ្រព្យសកម្មអរូបី ត្រូវបានរំលស់ផ្អែកលើវិធីសាស្ត្ររំលស់ថេរក្នុងរយៈពេល 10ឆ្នាំ។ ប្រសិនបើមានកែប្រែជា សារវន្តទៅលើអត្រារំលស់ អាយុកាលប្រើប្រាស់ ឬតម្លៃនៅសល់នៃទ្រព្យសកម្មអរូបីនោះ ត្រូវបានកំណត់ឡើងវិញដើម្បីឆ្លុះបញ្ចាំងនូវការប៉ាន់ស្មានថ្មី។

## ២២ ៩ ឱនភាពនៃតម្លៃ

### ទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

តម្លៃយោងនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ត្រូវបានត្រួតពិនិត្យឡើងវិញនៅរាល់កាលបរិច្ឆេទ របាយការណ៍នីមួយៗ ដើម្បីកំណត់ថាតើមានសញ្ញាណាមួយដែលបង្ហាញថាទ្រព្យសកម្មទាំងនោះមានឱនភាពនៃតម្លៃ។ ប្រសិនបើមានសញ្ញានោះកើតឡើង ការប៉ាន់ស្មានលើតម្លៃដែលអាចប្រមូលមកវិញបាននៃទ្រព្យសកម្មត្រូវបានធ្វើឡើង។

តម្លៃដែលអាចប្រមូលមកវិញបាននៃទ្រព្យសកម្ម ឬឯកតាបង្កើតសាច់ប្រាក់ គឺផ្អែកលើតម្លៃដែលធំជាងរវាងតម្លៃប្រើប្រាស់ និងតម្លៃសមស្របដកចំណាយលើការលក់ចេញ។ ក្នុងការប៉ាន់ប្រមាណតម្លៃប្រើប្រាស់លំហូរ សាច់ប្រាក់រំពឹងថានឹងទទួលបាននាពេលអនាគត ត្រូវបានធ្វើអប្បហារតម្លៃបច្ចុប្បន្នដោយប្រើអត្រាការប្រាក់មុនបង់ពន្ធដែលដែលឆ្លុះបញ្ចាំងការប៉ាន់ប្រមាណតម្លៃពេលវេលា ក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យ ជាក់លាក់សម្រាប់ទ្រព្យសកម្មទាំងនោះ។

សម្រាប់គោលបំណងនៃការត្រួតពិនិត្យលើឱនភាពនៃតម្លៃទ្រព្យសកម្ម ត្រូវបានដាក់បញ្ចូលគ្នាជាក្រុមទៅក្នុងក្រុមទ្រព្យសកម្មតូចៗបំផុត ដែលអាចបង្កើតជាលំហូរសាច់ប្រាក់ពីការប្រើប្រាស់ ដោយមិនពឹងផ្អែកលើលំហូរ សាច់ប្រាក់នៃទ្រព្យសកម្មដទៃទៀត ឬក្រុមទ្រព្យសកម្មដទៃទៀត ("ឯកតាបង្កើតសាច់ប្រាក់")។

ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានទទួលស្គាល់ប្រសិនបើតម្លៃយោងនៃទ្រព្យសកម្ម ឬឯកតាបង្កើត សាច់ប្រាក់មានចំនួនលើសពីតម្លៃដែលអាចប្រមូលបានមកវិញ។ ការខាតបង់លើឱនភាពនៃតម្លៃ ត្រូវបានកត់ត្រាជាចំណេញ ឬខាត។

## ២២ ១០ ប្រាក់កម្ចី និងបំណុលផ្សេងៗ

ប្រាក់កម្ចី និងបំណុលផ្សេងៗ ត្រូវបានកត់ត្រាតាមរំលស់ថ្លៃដើម ដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធភាពនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

## ២២ ១១ សំវិធានធន

សំវិធានធន ត្រូវបានទទួលស្គាល់នៅពេលដែលក្រុមហ៊ុនមានកាតព្វកិច្ចតាមផ្លូវច្បាប់ ឬកាតព្វកិច្ចប្រយោលនាពេលបច្ចុប្បន្ន ដែលជាលទ្ធផលនៃព្រឹត្តិការណ៍កន្លងផុតទៅ ហើយមានលទ្ធភាពដែលតម្រូវឱ្យមានលំហូរចេញនូវអត្ថប្រយោជន៍សេដ្ឋកិច្ចក្នុងការបំពេញនូវកាតព្វកិច្ចនោះ ហើយចំនួនសំវិធានធន ត្រូវបានប៉ាន់ស្មានប្រកបដោយភាពជឿជាក់។ សំវិធានធនត្រូវបានកំណត់ដោយអប្បហារលំហូរទឹកប្រាក់ ដែលរំពឹងថានឹងត្រូវទូទាត់នាពេលអនាគតដោយប្រើអត្រាមុនបង់ពន្ធ ដែលឆ្លុះបញ្ចាំងពីការប៉ាន់ប្រមាណនៃតម្លៃពេលវេលាក្នុងលក្ខខណ្ឌទីផ្សារបច្ចុប្បន្ន និងហានិភ័យជាក់លាក់ចំពោះបំណុលទាំងនោះ។ ការកើនឡើងនៃសំវិធានធនដោយសារពេលវេលា ត្រូវបានទទួលស្គាល់ជាចំណាយហិរញ្ញប្បទាន។

## ២២ ១២ អត្ថប្រយោជន៍និយោជិត

### *(ក) អត្ថប្រយោជន៍របស់និយោជិតរយៈពេលខ្លី*

អត្ថប្រយោជន៍របស់បុគ្គលិករយៈពេលខ្លីជាចំណាយ នៅពេលដែលសេវាកម្មពាក់ព័ន្ធត្រូវបានផ្តល់ជូន។ បំណុល ត្រូវបានទទួលស្គាល់ចំពោះចំនួនទឹកប្រាក់ដែលរំពឹងថានឹងត្រូវបង់ប្រសិនបើក្រុមហ៊ុនមាន កាតព្វកិច្ចតាមច្បាប់ ឬប្រយោលដើម្បីបង់ចំនួននេះ ដែលជាលទ្ធផលនៃសេវាកម្មកន្លងមកដែលផ្តល់ដោយបុគ្គលិក ហើយកាតព្វកិច្ចអាចត្រូវបានប៉ាន់ប្រមាណបានដោយភាពជឿជាក់។

### *(ខ) អត្ថប្រយោជន៍ពីការបញ្ឈប់ការងារ*

អត្ថប្រយោជន៍ពីការបញ្ឈប់ការងារ គឺជាសំណងដែលត្រូវបង់ជូននិយោជិតដោយការបញ្ឈប់ពីការងារមុនពេលថ្ងៃចូលនិវត្តន៍ ឬការស្ម័គ្រចិត្តរបស់និយោជិត ដើម្បីទទួលយកអត្ថប្រយោជន៍ទាំងនោះជាថ្នូរនឹងការបញ្ឈប់ពីការងារដោយការស្ម័គ្រចិត្ត។ អត្ថប្រយោជន៍ទាំងនោះត្រូវបានទទួលស្គាល់ជាបំណុល និងចំណាយនៅពេលដែលក្រុមហ៊ុនមានគម្រោងបញ្ឈប់ការងារនិយោជិតជាផ្លូវការច្បាស់លាស់ ដោយមិនមានលក្ខខណ្ឌណាដែលគម្រោងនេះត្រូវដកចេញ។ ក្នុងករណីការបញ្ឈប់ដោយស្ម័គ្រចិត្តពីនិយោជិត ដែលលើសពីតម្រូវការ អត្ថប្រយោជន៍នោះ ត្រូវបានគណនាផ្អែកទៅលើចំនួននិយោជិតដែលរំពឹងថានឹងទទួលតាមការស្នើសុំនេះ។

នៅពេលដែលអត្ថប្រយោជន៍ពីការបញ្ឈប់ការងារលើសពី 12ខែ បន្ទាប់ពីកាលបរិច្ឆេទរាយការណ៍ អត្ថប្រយោជន៍នោះត្រូវបានធ្វើអប្បហារតម្លៃបច្ចុប្បន្ន ដោយប្រើអត្រាទីផ្សារនៅចុងការិយបរិច្ឆេទ។

### *(ឥ) អត្ថប្រយោជន៍និយោជិតរយៈពេលវែងផ្សេងៗ*

កាតព្វកិច្ចរបស់ក្រុមហ៊ុនចំពោះអត្ថប្រយោជន៍និយោជិតរយៈពេលវែង ដែលរួមមានប្រាក់អតីតភាពការងារ គឺជាចំណាយលើអត្ថប្រយោជន៍ ដែលនិយោជិតត្រូវទទួលបានក្នុងការបំពេញការងារក្នុងការិយបរិច្ឆេទមុន និង បច្ចុប្បន្ន។ អត្ថប្រយោជន៍និយោជិតរយៈពេលវែង ត្រូវបានធ្វើអប្បហារដើម្បីកំណត់តម្លៃបច្ចុប្បន្ន។ ការវាស់វែងឡើងវិញត្រូវបានទទួលស្គាល់ជាចំណេញ ឬខាត។

## ២២ ១៣ ភាគលាភ

ភាគលាភដែលបានប្រកាស និងអនុម័តដោយភាគទុនិករបស់ក្រុមហ៊ុន មុនពេលចុងការិយបរិច្ឆេទ ត្រូវបានទទួលស្គាល់ថាជាបំណុល និងត្រូវបានកាត់ចេញពីប្រាក់ចំណេញរក្សាទុកនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ភាគលាភដែលបានប្រកាស និងអនុម័តដោយភាគទុនិករបស់ក្រុមហ៊ុនបន្ទាប់ពីកាលបរិច្ឆេទរាយការណ៍មិនត្រូវបានទទួលស្គាល់ថាជាបំណុលទេ ប៉ុន្តែត្រូវបានលាតត្រដាងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

## ២២ ១៤ ការប្រាក់

ចំណូល និងចំណាយការប្រាក់ត្រូវបានទទួលស្គាល់ជាចំណេញ ឬខាត ដោយប្រើវិធីសាស្ត្រការប្រាក់ ប្រសិទ្ធភាព។ អត្រាការប្រាក់ប្រសិទ្ធិភាព គឺជាអត្រាដែលធ្វើអប្បហារសាច់ប្រាក់ ដែលរំពឹងថាត្រូវទូទាត់ ឬទទួលបានពេលអនាគតតាមរយៈអាយុកាលដែលរំពឹងទុកនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ (ឬក្នុងករណី រយៈពេលខ្លីសមស្របមួយ) ឱ្យមកស្មើនឹងតម្លៃយោងនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។

នៅពេលគណនាអត្រាការប្រាក់ប្រសិទ្ធភាព ក្រុមហ៊ុនត្រូវប៉ាន់ស្មានលំហូរសាច់ប្រាក់នាពេលអនាគតដោយពិចារណាលើលក្ខខណ្ឌកិច្ចសន្យាទាំងអស់នៃឧបករណ៍ហិរញ្ញវត្ថុ ប៉ុន្តែមិនមែនការបាត់បង់ឥណទាននាពេលអនាគតទេ។

ការគណនាអត្រាការប្រាក់ប្រសិទ្ធិភាពរួមមានថ្លៃប្រតិបត្តិការ និងកម្រៃ និងពិន្ទុដែលបានបង់ ឬទទួលដែលជាផ្នែកភ្ជាប់នឹងអត្រាការប្រាក់ប្រសិទ្ធភាព។ ថ្លៃដើមប្រតិបត្តិការ រួមមានការចំណាយបន្ថែមដែលកើតឡើងដោយផ្ទាល់ទៅនឹងការទិញ ឬលក់ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ។

## ២២ ១៥ កម្រៃជើងសារ

ចំណូល និងចំណាយកម្រៃ និងជើងសារ ដែលភ្ជាប់នឹងអត្រាការប្រាក់ប្រសិទ្ធិភាពលើទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុត្រូវបានបញ្ចូលក្នុងការគណនាអត្រាការប្រាក់ប្រសិទ្ធិភាព។

ចំណូលកម្រៃ និងជើងសារផ្សេងៗ ត្រូវបានទទួលស្គាល់នៅពេលសេវាកម្មពាក់ព័ន្ធត្រូវបានបំពេញ។ ប្រសិនបើ កិច្ចសន្យាឥណទានមិនរំពឹងថានឹងមានការដកប្រាក់កម្ចី នោះថ្លៃសេវាដែលទាក់ទងនឹងប្រាក់កម្ចី ត្រូវបានទទួលស្គាល់ដោយផ្អែកលើមូលដ្ឋានថេរក្នុងរយៈពេលនៃកិច្ចសន្យាឥណទាន។

កម្រៃចំណាយ និងជើងសារផ្សេងៗ ពាក់ព័ន្ធនឹងចំណាយប្រតិបត្តិការ និងថ្លៃសេវាកម្ម ត្រូវបានកត់ត្រាជាចំណាយនៅពេលដែលសេវាកម្មបានទទួល។

## ២២ ១៦ ភតិសន្យា

ថ្លៃឈ្នួលដែលត្រូវទូទាត់លើភតិសន្យាប្រតិបត្តិការត្រូវបានកត់ត្រាជាចំណេញ ឬខាតតាមមូលដ្ឋានរំលស់ថេរទៅតាមថេរវេលានៃភតិសន្យា។

## ២២ ១៧ ពន្ធលើប្រាក់ចំណេញ

ពន្ធលើប្រាក់ចំណេញរួមមានពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងពន្ធពន្យារ។ ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ និងពន្ធពន្យារត្រូវបានទទួលស្គាល់ជាចំណេញ ឬខាត លើកលែងតែធាតុណាដែលបានទទួលស្គាល់ក្នុង របាយការណ៍ លទ្ធផលលម្អិតផ្សេងទៀត។

ពន្ធលើប្រាក់ចំណេញប្រចាំឆ្នាំ គឺជាពន្ធដែលរំពឹងថាត្រូវបង់ទៅលើប្រាក់ចំណេញជាប់ពន្ធប្រចាំឆ្នាំដោយប្រើ អត្រាពន្ធដែលបានអនុម័ត ឬបានអនុម័តជាអាទិ៍នៅកាលបរិច្ឆេទរាយការណ៍ និងនិយ័តភាពទាំងឡាយទៅលើពន្ធត្រូវបង់ពីឆ្នាំមុនៗ។

ពន្ធពន្យារត្រូវបានកំណត់ទៅលើភាពលំអៀងរវាងតម្លៃយោងនៃទ្រព្យសកម្ម និងបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ និងតម្លៃយោងសម្រាប់ការគិតពន្ធ (ហៅថាភាពលំអៀងបណ្តោះអាសន្ន)។

ពន្ធពន្យារជាបំណុល ត្រូវទទួលស្គាល់លើភាពលម្អៀងបណ្តោះអាសន្នដែលរំពឹងថា នឹងបង្កើនប្រាក់ចំណេញដែលជាប់ពន្ធនាពេលអនាគត។ ពន្ធពន្យារជាទ្រព្យសកម្មត្រូវបានទទួលស្គាល់សម្រាប់ភាពលំអៀងបណ្តោះអាសន្នទាំងឡាយណាដែលរំពឹងថានឹង កាត់បន្ថយប្រាក់ចំណេញជាប់ពន្ធនាពេលអនាគតរួមទាំងការខាតពន្ធ ឬឥណទានពន្ធដែលមិនទាន់បានប្រើប្រាស់ផ្សេងៗ។ ពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានទទួលស្គាល់តាមចំនួនដែលគិតថាអាចប្រើប្រាស់បានខ្ពស់បំផុត ដោយផ្អែកលើមូលដ្ឋានប្រាក់ចំណេញជាប់ពន្ធនាពេលបច្ចុប្បន្ន ឬនាពេលអនាគត ហើយមានលទ្ធភាពខ្ពស់ក្នុងការអាចយកមកប្រើប្រាស់បាន។

តម្លៃយោងសុទ្ធនៃពន្ធពន្យារជាទ្រព្យសកម្ម ត្រូវបានត្រួតពិនិត្យឡើងវិញនៅរៀងរាល់កាលបរិច្ឆេទរាយការណ៍ និងត្រូវបានធ្វើនិយ័តភាពដើម្បីឆ្លុះបញ្ចាំងពីការវាយតម្លៃប្រាក់ចំណេញជាប់ពន្ធនាពេលអនាគត។ និយ័តភាពទាំងនោះត្រូវបានទទួលស្គាល់ជាចំណេញ ឬខាតនៅក្នុងរបាយការណ៍លទ្ធផលលម្អិតលើកលែងតែនិយ័តភាពដែលពាក់ព័ន្ធនឹងខ្ទង់ចំណូល ឬចំណាយដែលត្រូវទទួលស្គាល់ក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗដោយ និយ័តភាពនោះត្រូវតែទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផលលម្អិតផ្សេងៗ។

ពន្ធពន្យារ ត្រូវបានគណនាតាមអត្រាពន្ធដែលប្រើសម្រាប់ការគណនាប្រាក់ចំណេញជាប់ពន្ធ (ការខាតពន្ធ) ក្នុងការិយបរិច្ឆេទដែលពន្ធពន្យារជាទ្រព្យសកម្មរំពឹងថានឹងប្រើប្រាស់បាន ឬបំណុលជាពន្ធពន្យារំពឹងថានឹងត្រូវទូទាត់ដោយប្រើអត្រាពន្ធដែលបានអនុម័ត ឬបានកំណត់ជាអាទិ៍នានៅសម្រាប់កាលបរិច្ឆេទរាយការណ៍។

## ២២ ១៨ ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុ

### *(ក) ការទទួលស្គាល់*

ក្រុមហ៊ុន ទទួលស្គាល់ដំបូងនូវទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុនៅពេលដែលក្រុមហ៊ុនបានក្លាយជា ភាគីនៃការផ្តល់កិច្ចសន្យានៃឧបករណ៍ហិរញ្ញវត្ថុ។

ទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ ដែលបានវាស់វែងដំបូងតាមតម្លៃសមស្របបូកនឹងចំណាយប្រតិបត្តិការដែលរួមចំណែកដោយផ្ទាល់ទៅលើការទិញ ឬលក់ឧបករណ៍នោះ។

### *(ខ) ចំណាត់ថ្នាក់*

ក្រុមហ៊ុនចាត់ចំណាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុលហិរញ្ញវត្ថុរបស់ខ្លួនជាឧបករណ៍ហិរញ្ញវត្ថុមូលដ្ឋាន ដែលមានចែងក្នុងផ្នែកទី 11 ឧបករណ៍ហិរញ្ញវត្ថុមូលដ្ឋាន។

*(ឥ)* ***ការឈប់ទទួលស្គាល់***

ក្រុមហ៊ុនឈប់ទទួលស្គាល់ទ្រព្យសកម្មហិរញ្ញវត្ថុ នៅពេលដែលសិទ្ធិទទួលបានសាច់ប្រាក់តាមកិច្ចសន្យានៃទ្រព្យសកម្មនោះផុតកំណត់ ឬក្រុមហ៊ុន បានផ្ទេរសិទ្ធិក្នុងការទទួលបានសាច់ប្រាក់តាមកិច្ចសន្យាក្នុងប្រតិបត្តិការដែលហានិភ័យ និងផលចំណេញនៃភាពជាម្ចាស់កម្មសិទ្ធិលើទ្រព្យសកម្ម ហិរញ្ញវត្ថុត្រូវបានផ្ទេរចេញ ឬក្នុងករណីមិនផ្ទេរចេញ ឬមិនរក្សាហានិភ័យ និងផលចំណេញនៃភាពជាម្ចាស់កម្មសិទ្ធិលើទ្រព្យសកម្មហិរញ្ញវត្ថុ និងមិនរក្សាការគ្រប់គ្រងទៅលើទ្រព្យសកម្មដែលផ្ទេរចេញ។

ក្រុមហ៊ុនឈប់ទទួលស្គាល់បំណុលហិរញ្ញវត្ថុ នៅពេលកាតព្វកិច្ចកិច្ចសន្យាត្រូវបានរំសាយ ឬលុបចោល ឬផុតកំណត់។

*(ឃ)* ***ការកាត់កង***

ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុត្រូវបានកាត់កង ហើយតម្លៃយោងសុទ្ធត្រូវបង្ហាញនៅក្នុងរបាយការណ៍ ស្ថានភាពហិរញ្ញវត្ថុ នៅពេលក្រុមហ៊ុនមានសិទ្ធិតាមផ្លូវច្បាប់ដើម្បីទូទាត់ និងមានបំណងធ្វើការទូទាត់លើ មូលដ្ឋានតម្លៃសុទ្ធ ឬដើម្បីទទួលស្គាល់ទ្រព្យសកម្ម និងទូទាត់បំណុលជាប្រចាំ។

*(ង)* ***ការវាស់វែងរំលស់ថ្លៃដើម***

រំលស់ថ្លៃដើមនៃទ្រព្យសកម្មហិរញ្ញវត្ថុ ឬបំណុលហិរញ្ញវត្ថុ គឺជាចំនួនដែលទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុល ហិរញ្ញវត្ថុ ដែលបានកត់ត្រាតាមប្រាក់ដើមដំបូង ដកការទូទាត់ប្រាក់ដើម បូក ឬដកចំនួនរំលស់បង្គរដោយប្រើវិធីសាស្ត្រការប្រាក់ប្រសិទ្ធិភាពនៃភាពខុសគ្នារវាងចំនួនទឹកប្រាក់ដែលបានទទួលស្គាល់ដំបូង និងចំនួនដល់កាលកំណត់ ដកឱនភាពនៃតម្លៃ។

*(ច)* ***ការវាស់វែងតម្លៃសមស្រប***

តម្លៃសមស្រប គឺជាតម្លៃដែលគួរទទួលបានដើម្បីលក់ទ្រព្យសកម្ម ឬបង់ដើម្បីផ្ទេរបំណុល ក្នុងប្រតិបត្តិការរៀបរយ រវាងអ្នកចូលរួមទីផ្សារនៅកាលបរិច្ឆេទវាស់វែងជាគោល ឬក្នុងករណីមិនមាន ត្រូវយកទីផ្សារដែលមានអត្ថប្រយោជន៍បំផុតដែលក្រុមហ៊ុនទទួលបាននៅកាលបរិច្ឆេទនោះ។ តម្លៃសមស្របនៃបំណុលការឆ្លុះបញ្ចាំងពីហានិភ័យមិនដំណើរការរបស់វានោះទេ។

ប្រសិនបើអាចក្រុមហ៊ុនវាស់វែងតម្លៃសមស្រប ដោយប្រើប្រាស់តម្លៃប៉ាន់ស្មានដែលបានដកស្រង់ពីទីផ្សារសកម្មសម្រាប់ឧបករណ៍ហិរញ្ញវត្ថុនោះ។ ទីផ្សារត្រូវបានចាត់ទុកថាសកម្មប្រសិនបើប្រតិបត្តិការសម្រាប់ទ្រព្យសកម្ម ឬបំណុលត្រូវកើតឡើងដោយមានបរិមាណគ្រប់គ្រាន់ដើម្បីផ្តល់ព័ត៌មានអំពីតម្លៃជាប្រចាំ។

ប្រសិនបើមិនមានតម្លៃប៉ាន់ស្មានពីទីផ្សារសកម្មទេនោះ ក្រុមហ៊ុនអាចប្រើបច្ចេកទេសវាយតម្លៃដែលប្រើប្រាស់ធាតុចូលដែលអាចសង្កេតបានជាអតិបរមា និងកាត់បន្ថយការប្រើប្រាស់ធាតុចូលដែលមិនអាចអង្កេតបានជា អតិបរមា។ បច្ចេកទេសវាយតម្លៃដែលត្រូវបានជ្រើសរើសរួមបញ្ចូលកត្តាទាំងអស់ ដែលអ្នកចូលរួមក្នុងទីផ្សារពិចារណាលើការកំណត់តម្លៃប្រតិបត្តិការ។

ភស្តុតាងល្អបំផុតនៃតម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុ នៅពេលទទួលស្គាល់ដំបូងជាធម្មតា គឺជាតម្លៃ ប្រតិបត្តិការធម្មតា ឧទាហរណ៍ តម្លៃសមស្របនៃតម្លៃតបស្នងដែលបានផ្តល់ឱ្យ ឬទទួលបាន។ ប្រសិនបើក្រុមហ៊ុនកំណត់ថាតម្លៃសមស្របនៅពេលទទួលស្គាល់ដំបូង ខុសគ្នាពីតម្លៃប្រតិបត្តិការ ហើយតម្លៃសមស្របមិនមានការបញ្ជាក់ពីសម្រង់តម្លៃពីទីផ្សារសកម្មសម្រាប់ទ្រព្យសកម្ម ឬបំណុលស្រដៀងគ្នា និងមិនផ្អែកលើបច្ចេកទេសវាយតម្លៃ ដែលប្រើប្រាស់ទិន្នន័យពីទីផ្សារដែលអាចសង្កេតបាននោះឧបករណ៍ហិរញ្ញវត្ថុត្រូវបានវាស់វែងដំបូងតាមតម្លៃសមស្រប ដោយនិយតកម្មដើម្បីពន្យារភាពខុសគ្នារវាងតម្លៃសមស្របនៃការទទួលស្គាល់ដំបូង និងតម្លៃ ប្រតិបត្តិការ។

បន្ទាប់មកភាពខុសគ្នានោះ ត្រូវបានទទួលស្គាល់ជាចំណេញ ឬខាតដោយផ្អែកលើមូលដ្ឋាន សមស្របទៅតាមអាយុកាលឧបករណ៍ ប៉ុន្តែមិនយូរជាងពេលដែលធ្វើការវាយតម្លៃ គឺត្រូវបានគាំទ្រទាំងស្រុងដោយទិន្នន័យទីផ្សារដែលអាចសង្កេតបាន ឬប្រតិបត្តិការត្រូវបានបិទ។

(ឆ) *ការកំណត់អត្តសញ្ញាណ និងការវាស់វែងនៃឱនភាព*

**ភស្តុតាងដែលបញ្ជាក់ពីឱនភាព**

នាកាលបរិច្ឆេទរាយការណ៍នីមួយៗ ក្រុមហ៊ុនវាយតម្លៃថាតើមានភស្តុតាងជាក់ស្តែងនៃទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានវាស់វែងដោយថ្លៃដើម ឬរំលស់ថ្លៃដើមមានសញ្ញាណឱនភាពឬទេ។ ទ្រព្យសកម្មហិរញ្ញវត្ថុ ឬក្រុមទ្រព្យសកម្មហិរញ្ញវត្ថុមានឱនភាពនៅពេលមានភស្តុតាងបង្ហាញថាព្រឹត្តិការណ៍ខាតបង់បានកើតឡើង បន្ទាប់ពីការទទួលស្គាល់ដំបូងនៃទ្រព្យសកម្ម ហើយព្រឹត្តិការណ៍បាត់បង់មានផលប៉ះពាល់ដល់លំហូរសាច់ប្រាក់ នាពេលអនាគតនៃទ្រព្យសកម្មដែលអាចប៉ាន់ស្មានបាន។

ភស្តុតាងដែលបញ្ជាក់ថាទ្រព្យសកម្មមានឱនភាពរួមមាន៖

- ការលំបាកផ្នែកហិរញ្ញវត្ថុជាសារវន្តរបស់អ្នកខ្ចី ឬអ្នកបោះផ្សាយ
- ភាពយឺតយ៉ាវ ឬការមិនទូទាត់សងដោយអ្នកខ្ចី
- ការរៀបចំឡើងវិញនូវលក្ខខណ្ឌទូទាត់សង ដែលក្រុមហ៊ុនមិនបានរំពឹងទុក
- សញ្ញាណបង្ហាញថាកូនបំណុលនឹងជួបប្រទះការក្ស័យធន
- ការបាត់បង់នៃទីផ្សារសកម្មសម្រាប់មូលប័ត្រ ឬ
- ទិន្នន័យដែលអាចសង្កេតបានទាក់ទងទៅនឹងក្រុមនៃទ្រព្យសកម្ម ដូចជាការផ្លាស់ប្តូរអវិជ្ជមាននៃស្ថានភាពទូទាត់របស់កូនបំណុល ឬអ្នកបោះផ្សាយនៅក្នុងក្រុម ឬលក្ខខណ្ឌសេដ្ឋកិច្ចដែលទាក់ទងគ្នានៅក្នុងក្រុម។

**ការវាយតម្លៃទោល និងជាក្រុម**

រាល់ទ្រព្យសកម្មទោលសារវន្ត ត្រូវបានវាយតម្លៃផ្សេងៗពីគ្នាចំពោះឱនភាព។

ទ្រព្យសកម្មដែលត្រូវបានគេរកឃើញថា មិនមានឱនភាពត្រូវបានវាយតម្លៃជាក្រុមលើឱនភាពដែលបានកើតឡើង ប៉ុន្តែមិនទាន់បានកំណត់បញ្ជាក់នៅឡើយ។

សមាសធាតុនីមួយៗនៃសំវិធានធនលើឱនភាព ត្រូវអនុវត្តទៅលើទ្រព្យសកម្មហិរញ្ញវត្ថុដែលត្រូវបានវាយតម្លៃទោលចំពោះឱនភាព ហើយត្រូវបានគេរកឃើញថាមានឱនភាព ហើយផ្អែកលើការប៉ាន់ស្មានដ៏ប្រសើរបំផុតរបស់អ្នកគ្រប់គ្រងលើតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់ ដែលរំពឹងថានឹងទទួលបាន។ ក្នុងការប៉ាន់ស្មានលំហូរសាច់ប្រាក់ទាំងនេះ អ្នកគ្រប់គ្រងធ្វើការវិនិច្ឆ័យអំពីស្ថានភាពហិរញ្ញវត្ថុរបស់កូនបំណុល និងតម្លៃដែលអាចកំណត់បាននៃទ្រព្យបញ្ចាំណាមួយ។

ឱនភាពនៃទ្រព្យសកម្មនីមួយៗ ត្រូវបានវាយតម្លៃលើគុណប្រយោជន៍របស់វា ហើយយុទ្ធសាស្ត្រ និងការប៉ាន់ប្រមាណលំហូរសាច់ប្រាក់ដែលអាចរកបានមកវិញត្រូវបានអនុម័តដោយអ្នកគ្រប់គ្រងដោយឯករាជ្យ។

សមាសធាតុជាក្រុមនៃសំវិធានធន ត្រូវបានបង្កើតឡើងសម្រាប់៖

- ក្រុមនៃប្រាក់កម្ចីមានលក្ខណៈដូចគ្នាដែលមិនត្រូវបានចាត់ទុកថាមានលក្ខណៈសារវន្តទោល និង
- ក្រុមនៃទ្រព្យសកម្មដែលមានលក្ខណៈសារវន្តទោល ប៉ុន្តែមិនត្រូវបានគេរកឃើញថាមានឱនភាព

សំវិធានធនជាក្រុមនៃប្រាក់កម្ចីដែលមានលក្ខណៈដូចគ្នាត្រូវបាន បង្កើតឡើងដោយប្រើវិធីសាស្ត្រស្ថិតិ ដូចជាវិធីសាស្ត្រអត្រាបន្ត ឬសម្រាប់បណ្តុំឥណទានតូចៗ ដែលមានព័ត៌មានមិនគ្រប់គ្រាន់ ឬរូបមន្តផ្អែកលើបទពិសោធន៍ អត្រាការខាតបង់យោងតាមនិន្នាការពីមុន។

ក្នុងការវាយតម្លៃសំវិធានធនលើឱនភាពជាក្រុម គណៈគ្រប់គ្រងពិចារណាលើកត្តាដូចជា គុណភាពឥណទាន ទំហំឥណទាន ការប្រមូលផ្តុំ និងកត្តាសេដ្ឋកិច្ច។ ដើម្បីប៉ាន់ប្រមាណនូវសំវិធានធនចាំបាច់ ការប៉ាន់ស្មានត្រូវបានបង្កើតឡើងដើម្បីកំណត់ពីរបៀបការខាតបង់ជាយថាផល ត្រូវបានកំណត់ និងតម្រូវបញ្ចូលប៉ារ៉ាម៉ែត្រ ដែលផ្អែកលើបទពិសោធន៍ពីមុន និងស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ន។ ភាពត្រឹមត្រូវនៃសំវិធានធនអាស្រ័យលើការសន្មត ម៉ូដែល និងប៉ារ៉ាម៉ែត្រដែលត្រូវបានប្រើក្នុងការកំណត់សំវិធានធនរួម។

**ការវាស់វែង**

សំវិធានធនលើឱនភាពនៃតម្លៃនៃទ្រព្យសកម្ម វាស់វែងតាមរំលស់ថ្លៃដើម ត្រូវបានគណនាជាភាពខុសគ្នារវាងតម្លៃយោង និងតម្លៃបច្ចុប្បន្ននៃលំហូរសាច់ប្រាក់នាពេលអនាគត ដែលត្រូវបានកាត់បន្ថយតាមអត្រាការប្រាក់ប្រសិទ្ធភាពដំបូងនៃទ្រព្យសកម្មនោះ។

**តំហយនៃឱនភាព និងការលុបចោល**

ប្រសិនបើក្នុងរយៈពេលជាបន្តបន្ទាប់ចំនួននៃតម្លៃឱនភាពមានការថយចុះ ហើយការថយចុះអាចទាក់ទងទៅនឹងព្រឹត្តិការណ៍ដែលកើតឡើងបន្ទាប់ពីឱនភាពត្រូវបានទទួលស្គាល់ ក្រុមហ៊ុនត្រូវដកចេញការខាតបង់នៃឱនភាព ដែលបានទទួលស្គាល់ពីមុនដោយផ្ទាល់ ឬដោយនិយ័តភាពគណនីសំវិធានធន។

តំហយសំវិធានធន មិនអាចលើសពីតម្លៃយោងនៃទ្រព្យសកម្មហិរញ្ញវត្ថុ (ដកសំវិធានធន) ដែលលើសពីចំនួនតម្លៃយោងដែលឱនភាពតម្លៃមិនត្រូវបានទទួលស្គាល់ពីមុន។ ក្រុមហ៊ុនត្រូវទទួលស្គាល់ចំនួនទឹកប្រាក់កែតម្រូវនៅក្នុងចំណេញ ឬខាត។

ក្រុមហ៊ុនលុបចោលបំណុល ឬបំណុលវិនិយោគមួយផ្នែកខ្លះ ឬទាំងអស់ដែលពាក់ព័ន្ធនឹងសំវិធានធនលើ ឱនភាពតម្លៃនៅពេលដែលអ្នកគ្រប់គ្រងកំណត់ថាមិនមានលទ្ធភាពមិនអាចប្រមូលមកវិញ។

## ២២ ១៩ ទុនបម្រុងតាមបទប្បញ្ញត្តិ

ធនាគារជាតិនៃកម្ពុជាបានចេញសេចក្តីប្រកាសលេខ ធ៧-០១៧-៣៤៤ ចុះថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមតែរមិន និងសារាចរលេខ ធ៧-០១៨-០០១ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៨ ស្តីពីការអនុវត្តប្រកាសស្តីពីការផ្តល់ចំណាត់ថ្នាក់ហានិភ័យឥណទាន និងសំវិធានធនលើអ៊ីមតែរមិន ដែលតម្រូវ អោយគ្រឹះស្ថានធនាគារ និងស្ថាប័នហិរញ្ញវត្ថុទាំងអស់ អនុវត្តការវាស់វែង ការធ្វើសំវិធានធនឥណទាន ដោយផ្អែកតាមអត្រាហានិភ័យឥណទានដូចខាងក្រោម៖

| **ចំណាត់ថ្នាក់** | **ចំនួនថ្ងៃដែលផុតកំណត់** | **សំវិធានធន** |
|---|---|---|
| **ឥណទានរយៈពេលខ្លី (តិចជាង១ឆ្នាំ)៖** | | |
| ស្តង់ដារ | ពី ០ ទៅ ១៤ ថ្ងៃ | ១% |
| ឃ្លាំមើល | ពី ១៥ ទៅ ៣០ ថ្ងៃ | ៣% |
| ក្រោមស្តង់ដារ | ពី ៣១ ទៅ ៦០ ថ្ងៃ | ២០% |
| ជាប់សង្ស័យ | ពី ៦១ ទៅ ៩០ ថ្ងៃ | ៥០% |
| បាត់បង់ | ៩១ ថ្ងៃ ឬច្រើនជាង | ១០០% |
| **ឥណទានរយៈពេលវែង (លើសពី១ឆ្នាំ)៖** | | |
| ស្តង់ដារ | ពី ០ ទៅ ២៩ ថ្ងៃ | ១% |
| ឃ្លាំមើល | ពី ៣០ ទៅ ៨៩ ថ្ងៃ | ៣% |
| ក្រោមស្តង់ដារ | ពី ៩០ ទៅ ១៧៩ ថ្ងៃ | ២០% |
| ជាប់សង្ស័យ | ពី ១៨០ ទៅ ៣៥៩ ថ្ងៃ | ៥០% |

| | | |
|---|---|---|
| បាត់បង់ | ៣៦០ ថ្ងៃ ឬច្រើនជាង | ១០០% |

យោងតាមមាត្រាទី៧៣ ក្រុមហ៊ុនត្រូវតែធ្វើការប្រៀបធៀបសំវិធានធនគណនាស្របតាមបទប្បញ្ញត្តិនៃធនាគារជាតិនៃកម្ពុជា និង សំវិធានធនគណនាតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់ សហគ្រាសធុនតូច និងមធ្យមៈ

(ក) ប្រសិនបើសំវិធានធនតាមបទប្បញ្ញត្តិទាបជាង ក្រុមហ៊ុនត្រូវកត់ត្រាសំវិធានធនដែលបានគណនាស្របតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម និង

(ខ) ប្រសិនបើសំវិធានធនតាមបទប្បញ្ញត្តិធំជាង ក្រុមហ៊ុនត្រូវកត់ត្រាសំវិធានធនដែលបានគណនាស្របតាម ស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា សម្រាប់សហគ្រាសធុនតូច និងមធ្យម និងផ្ទេរភាពខុសគ្នាពីប្រាក់ចំណេញរក្សាទុកទៅក្នុងគណនីទុនបម្រុងតាមបទប្បញ្ញត្តិក្នុងគណនីមូលធន។

## ២២ ២០ សម្ព័ន្ធញាតិ

សហគ្រាស និងបុគ្គលដែលទាក់ទងផ្ទាល់ ឬមិនផ្ទាល់តាមរយៈអន្តរការីមួយឬច្រើន ឬត្រូវបានគ្រប់គ្រង ក្រោមការគ្រប់គ្រងរួមជាមួយក្រុមហ៊ុន រួមទាំងក្រុមហ៊ុនមេ បុត្រសម្ព័ន្ធ និងក្រុមហ៊ុនសម្ព័ន្ធផ្សេងទៀតដែលជាភាគីពាក់ព័ន្ធរបស់ក្រុមហ៊ុន។ ក្រុមហ៊ុនសមាគត និងបុគ្គលដែលកាន់កាប់ដោយផ្ទាល់ ឬប្រយោលលើសិទ្ធបោះឆ្នោតរបស់ក្រុមហ៊ុន ដែលផ្តល់ឱ្យពួកគេមានឥទ្ធិពលយ៉ាងសំខាន់មកលើសហគ្រាស គណៈគ្រប់គ្រងសំខាន់ៗរួមមាន នាយក និងបុគ្គលិកក្រុមហ៊ុន និងសមាជិកជិតស្និទ្ធជាមួយក្រុមគ្រួសាររបស់បុគ្គលនោះ ក៏ដូចជាក្រុមហ៊ុនដែលសហការជាមួយបុគ្គលទាំងនេះ ត្រូវបានចាត់ទុកជាភាគីពាក់ព័ន្ធផងដែរ។

## ២៣ តួលេខប្រៀបធៀប

(ក) ក្នុងអំឡុងពេលការរៀបចំរបាយការណ៍ហិរញ្ញវត្ថុសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ អ្នកគ្រប់គ្រងបានរកឃើញការបង្ហាញខុសនៃការប្រើប្រាស់អត្រាប្តូរប្រាក់មធ្យម ដើម្បីប្តូរពីប្រាក់ដុល្លារអាមេរិកទៅជាប្រាក់រៀលក្នុងរបាយការណ៍លទ្ធផលលម្អិត បម្រែបម្រួលមូលធន លំហូរសាច់ប្រាក់ និងកំណត់សម្គាល់ពាក់ព័ន្ធផ្សេងៗសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។ អ្នកគ្រប់គ្រងបានកំណត់ឡើងវិញនូវតួលេខប្រៀបធៀបជាប្រាក់រៀលសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១។

(ខ) តួលេខប្រៀបធៀបខាងក្រោមត្រូវបានចាត់ថ្នាក់ឡើងវិញ ដើម្បីអនុលោមតាមបទបង្ហាញនៃរបាយការណ៍បច្ចុប្បន្ន។

| | នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២១ | | | |
|---|---|---|---|---|
| | តួលេខកំណត់ឡើងវិញ | | តួលេខបង្ហាញពីមុន | |
| | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) | ដុល្លារអាមេរិក | ពាន់រៀល (កំណត់សម្គាល់២.៤) |
| **របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ** | | | | |
| **ទ្រព្យសកម្ម** | | | | |
| ឥណទានផ្ដល់ដល់អតិថិជន | ៣,៩៩២,៩០៤ | ១៦,២៦៧,០៩១ | ៤,០២៦,៦១៨ | ១៦,៤០៤,៤៤២ |
| ទ្រព្យសកម្មផ្សេងៗ | ៤៤,៤៩៨ | ១៨១,២៨៥ | ៩៩,៧៦០ | ៤០៦,៤២២ |
| **បំណុល** | | | | |
| ប្រាក់កម្ចី | ១,២១១,២៥៦ | ៤,៩៣៤,៦៥៧ | ១,០៦៣,៣០០ | ៤,៣៣១,៨៨៤ |
| បំណុលផ្សេងៗ | ១៥,៥១៧ | ៦៣,២១៦ | ២៥២,៤៤៩ | ១,០២៨,៤៧៧ |